ធម៌ប្រតិបត្តិសម្រាប់ជីវិតប្រចាំថ្ងៃ

**Mental Development in Daily life**

# ព្រហ្មយាន

## ភាគទី ៣

ពោលអំពី

**មគ្គប្បដិបទា**

ព.ស. ២៥៤៨

❖❖❖❖❖❖❖

( ធម្មទាន )

ហាយ ចំរើន - អ៊ឹម រ៉ៃយ៉ា

# អារម្ភកថា

ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ។ លុះភិក្ខុនោះអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើនសូមព្រះមានព្រះភាគទ្រង់សំដែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ។ បេ ។ ខ្ញុំព្រះអង្គនឹងមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុកាលត្រេកអរ ឈ្មោះថា ជាប់ ( អន្ទាក់ ) មារ កាលភិក្ខុមិនត្រេកអរ ឈ្មោះថា រួចចាក ( អន្ទាក់ ) មារមានចិត្តបាប ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គយល់ហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គយល់ហើយ ។ ម្នាលភិក្ខុ ចុះភាសិតដែលតថាគតសំដែងដោយសង្ខេប តើអ្នកយល់សេចក្តីដោយពិស្តារដូចម្តេចទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុកាលត្រេកអរនូវរូប ។ នូវវេទនា ។ នូវសញ្ញា ។ នូវសង្ខារ ។ នូវវិញ្ញាណ ឈ្មោះថា ជាប់ ( អន្ទាក់ ) មារ កាលបើមិនត្រេកអរទេ ឈ្មោះថា រួចចាក ( អន្ទាក់ ) មារមានចិត្តបាប ។ ម្នាលភិក្ខុ ប្រពៃហើយ ៗ ម្នាលភិក្ខុ ត្រូវណាស់ហើយ ។ ......។

សម្គាល់ :

ស- ការសួរ

ឆ- ការឆ្លើយ

---



# ពាក្យឧទ្ទិស

ក្រោយពីបានរៀបរៀងចប់ យើងខ្ញុំបានយកសៀវភៅនេះទៅប្រគេនព្រះភិក្ខុ ៖

ប៉ូច សុផល គង់នៅអាស្រមព្រះគន្ធកុដិ

សោម រឿយ គង់នៅអាស្រមព្រះគន្ធកុដិ

ឧបាសក សន ម៉ារឌី

ជួយផ្ទៀងផ្ទាត់ន័យសេចក្តី និងអក្ខរៈ ឃើញថាអាចបោះពុម្ពដើម្បីសិក្សាបាន ។

សូមឧទ្ទិសបុណ្យ ដែលកើតពីសៀវភៅធម៌នេះដល់ ៖

បុព្វការីជន គឺ មាតា.បិតា គ្រូអាចារ្យ ព្រមទាំងញាតិក្នុងសង្សារវដ្ត សូមលោកទាំងឡាយបានទទួលនូវចំណែកបុណ្យនេះ ឲ្យបានស្មើ ៗ គ្នា ។ សូមអនុមោទនា ............. !

បាត់ដំបង , ថ្ងៃអាទិត្យ ១០ កើត ខែ កត្តិក ព.ស. ២៥៤៨

២១ - ១១ - ២០០៤

ហាយ ចំរើន , អ៊ឹម វ៉ៃយ៉ា

ស- ខ្ញុំដឹងថា ការចម្រើនសតិប្បដ្ឋានមានប្រយោជន៍ ប៉ុន្តែខ្ញុំនៅមិនទាន់ដឹងថា នឹងចម្រើនសតិក្នុងជីវិតប្រចាំថ្ងៃ បានដូចម្ដេច តើពេលណាគប្បីចម្រើនសតិប្បដ្ឋាន ព្រោះខ្ញុំជាប់រវល់ធ្វើការងារ ។

ឆ- ការចម្រើនសតិប្បដ្ឋាន គឺជាការសិក្សាដឹងអំពីជីវិតប្រចាំថ្ងៃពិត ។ ដឹងចំពោះការងារ ដឹងចំពោះខ្លួនឯង តើសេចក្ដីពិតយ៉ាងណា តែថាមនុស្សយើងច្រើនតែចង់ដឹងរឿងរបស់អ្នកដទៃ ក្រៅអំពីខ្លួនឯង ព្រះមានព្រះភាគទ្រង់ប្រៀនប្រដៅថា ការចេះដឹងចំពោះខ្លួនឯង ប្រសើរជាងការដឹងរឿងអ្នកដទៃ ។

ក្នុងវិសុទ្ធិមគ្គ ឥន្ទ្រិយវិធនិទ្ទេស មានសេចក្ដីថា ព្រះមានព្រះភាគទ្រង់ធ្វើមិនឲ្យព្រះនាងអនោជាទេវី និង ស្រីបរិវារ ១ ពាន់នាក់ ដែលមកតាមរកព្រះមហាកប្បិនព្រមទាំងបរិវារ ឃើញ សូម្បីអង្គុយក្នុងទីជិតព្រះអង្គ ព្រះនាងទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើនព្រះអង្គទ្រង់ឃើញព្រះរាជាដែរឬទេ ?” ព្រះមានព្រះភាគត្រាស់ថា “ ព្រះនាងត្រូវការស្វែងរកព្រះរាជាប្រសើរឬ ឬស្វែងរកខ្លួនឯងប្រសើរជាង ” ព្រះនាងទើបទូលថា “ ស្វែងរកខ្លួនឯងប្រសើរជាង ព្រះអង្គ ” ដូច្នេះ ទើបទ្រង់សម្ដែង



ធម៌ដល់ព្រះនាងអនោជាទេវី ដែលប្រថាប់គង់ហើយនោះ ធ្វើឲ្យព្រះនាងព្រមទាំងបរិវារ ១ ពាន់នាក់ តាំងនៅក្នុងសោតាបត្តិផល ឲ្យពួកអាមាត្យតាំងនៅក្នុងអនាគាមិផល ឲ្យព្រះរាជាតាំងនៅក្នុងអរហត្តផល ។

ការចម្រើនសតិប្បដ្ឋាន មិនមែនអ្វីដែលក្រៅអំពីជីវិតប្រចាំថ្ងៃទេ គឺការមានសតិរលឹកដឹងលក្ខណៈរបស់នាម និង រូប ដែលប្រាកដក្នុងជីវិតប្រចាំថ្ងៃនោះ គឺ ការចម្រើនមគ្គមានអង្គ ៨ ។ បើមានអ្នកណាគេពោលថា មិនមានពេលវេលាចម្រើនសតិប្បដ្ឋានវិបស្សនា ក៏ព្រោះគេមិនទាន់យល់ថា មគ្គមានអង្គ ៨ នោះ គឺអ្វី ។

ស- មគ្គមានអង្គ ៨ នោះ គឺអ្វី ដូចគ្នានឹងសតិទេ ហើយចាំ បាច់ទេចំពោះការដឹងច្បាស់អរិយសច្ចធម៌ នឹងធ្វើឲ្យយើងមានសេចក្ដីសុខច្រើន និង ជួយឲ្យយើងធ្វើមុខនាទីរបស់យើងបានល្អប្រសើរ ។

ឆ- បើពោលដល់សភាវធម៌ ក៏គួរនឹងដឹងថា សភាវៈនោះ ជាធម៌ប្រភេទណា មិនដូច្នោះ ក៏នឹងយល់មិនបានច្បាស់មគ្គមានអង្គ ៨ នោះជាបរមត្ថធម៌ប្រភេទណា បរមត្ថធម៌មាន ៤ ប្រភេទ គឺ ចិត្ត ចេតសិក រូប និង និព្វាន ។ មគ្គមានអង្គ ៨ ជាចេតសិកទាំង ៨ ជាសោភណ-

ចេតសិក កើតជាមួយសោភណចិត្ត ដែលរលឹកដឹងលក្ខណៈរបស់នាម និង រូប ។ ការរលឹកដឹងលក្ខណៈណារបស់នាម និង រូប ជាការចម្រើនមគ្គមានអង្គ ៨ , ខណៈណាចេតសិកធម៌ដែលជាមគ្គមានអង្គ ៨ មិនកើតជាមួយលោកុត្តរចិត្ត ចិត្តដែលដឹងច្បាស់និព្វាន ខណៈនោះ ក៏ជាលោកិយធម៌ ខណៈណាចេតសិកដែលជាមគ្គមានអង្គ ៨ កើតជាមួយលោកុត្តរចិត្ត ខណៈនោះ ក៏ជាលោកុត្តរមគ្គ ។

សូមសួរថា មគ្គមានអង្គ ៨ ដូចគ្នានឹងសតិទេ , សតិជាអង្គមួយក្នុងមគ្គមានអង្គ ៨ គឺជា សម្មាសតិ ការរលឹកត្រូវ យើងជ្រាបហើយថាសតិកើតជាមួយសោភណចិត្ត សតិជាសម្មាសតិក្នុងមគ្គមានអង្គ ៨ កាល កើតរួមជាមួយបញ្ញា ដែលឃើញត្រូវក្នុងលក្ខណៈរបស់នាមធម៌ រូបធម៌ ដែលប្រាកដតាមផ្លូវ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ខណៈណា ដែលសតិកើតឡើង រលឹកដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ ដែលប្រាកដ ខណៈនោះក៏ជាការចម្រើនមគ្គមានអង្គ ៨ ។

ស- បើដូច្នោះ អារម្មណ៍របស់មគ្គមានអង្គ ៨ នោះ ក៏គឺ លក្ខណៈរបស់នាមធម៌ រូបធម៌ ដែលប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត



កាយ ចិត្ត មែនទេ ។

ធ- ត្រូវហើយ

ស- បានដឹងថា អារម្មណ៍របស់មគ្គមានអង្គ ៨ នោះ គឺជាមហាសតិប្បដ្ឋាន ៤ គឺ កាយ វេទនា ចិត្ត ធម៌ , សំឡេង ជាសតិប្បដ្ឋានបានទេ ។

ធ- សំឡេង មានពិតឬទេ

ស- មានពិត

ធ- ហេតុដូចម្តេចបានជាពោលថា សំឡេងមានពិត

ស- អ្នកណា ៗ ក៏បានឮសំឡេងតាមផ្លូវត្រចៀក

ធ- បើសំឡេងជាវត្ថុដឹងបានតាមផ្លូវត្រចៀក នឹងមិនគួររលឹកដឹងលក្ខណៈរបស់សំឡេងឬ ?

ស- គួរ

ធ- សំឡេងជាអារម្មណ៍មួយក្នុងមហាសតិប្បដ្ឋាន ព្រោះសំឡេងមានពិត និងដឹងបានតាមផ្លូវត្រចៀក បើរលឹកដឹងលក្ខណៈរបស់សំឡេងរឿយ ៗ ញយ ៗ ក៏នឹងដឹងថា សំឡេង ជារូបធម៌មួយប្រភេទដែលកើត

ឡើង ហើយរលត់ទៅវិញជាធម្មតា ។

ស- ការដឹងថា ជាទុក្ខ ជាសតិប្បដ្ឋានឬទេ ?

ឆ- ការដឹងថា ជាទុក្ខ មានពិតទេ

ស- មានពិត ៗ

ឆ- បើមានពិត ក៏ជាសតិប្បដ្ឋាន គ្រប់វត្ថុដែលជាសភាវធម៌មាន ពិត ដឹងបានតាមផ្លូវ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ជាសតិប្បដ្ឋាន សតិរលឹងដឹងបានគ្រប់វេលា ។

ប្រសិនបើសួរថា មគ្គមានអង្គ ៨ ចាំបាច់ឬទេ ក្នុងការដឹងច្បាស់អរិយសច្ចធម៌ គឺ ជាការចាំបាច់ណាស់ ព្រោះមិនមានផ្លូវដទៃទៀតឡើយ កាលដឹងច្បាស់អរិយសច្ចធម៌ថ្នាក់ដំបូង គឺសោតាបន្នៈ ក៏រំលត់ការឃើញខុសថា មានតួខ្លួនបានដោយសមុច្ឆេទដោយការចម្រើនបញ្ញាដឹងសភាវ-ធម៌តាមសេចក្តីពិតថា មានតែនាមធម៌ និង រូបធម៌ប៉ុណ្ណោះ ក្រៅពីនាមធម៌ និង រូបធម៌ មិនមានអ្វីឡើយ ។

សូមសួរបន្ថែមទៀតថា មគ្គមានអង្គ ៨ នឹងធ្វើឲ្យយើងមានសេចក្តីសុខច្រើនឬ ? នឹងជួយយើងឲ្យបដិបត្តិនូវមុខនាទីបានកាន់តែល្អឬ ?



កិលេសរបស់យើង ធ្វើឲ្យយើងមិនមានសេចក្តីសុខ និង គ្រាខ្លះក៏ដឹងថា ជីវិតនេះជួបប្រទះការលំបាកពិតៗ ខណៈដែលកំពុងចម្រើនមគ្គមានអង្គ ៨ នោះ កិលេសក៏មិនទាន់រលត់អស់ តែក៏មានបញ្ញាបានដឹងសេចក្តីពិតរបស់ជីវិតច្រើនឡើង បើមិនយល់ដឹងអំពីជីវិតរបស់ខ្លួនឯងច្រើនឡើង ការជាប់ជំពាក់ជាមួយអ្នកដទៃ ក៏មានការផ្លាស់ប្តូរ យើងនឹងបានយល់ដល់អ្នកដទៃច្រើនឡើងនិងមានសេចក្តីមេត្តាករុណាច្រើនឡើងកាលបើចម្រើនសតិប្បដ្ឋាន ក៏ជាបច្ច័យឲ្យកើតកុសលចិត្តច្រើនឡើង ពេលធ្វើកិច្ចការងារប្រចាំថ្ងៃដោយកុសលចិត្ត អ្នកមានគិតទេថា នឹងធ្វើការងារបានយ៉ាងល្អប្រសើរយ៉ាងណា ។

ស- សូមលោកប្រាប់ថា មគ្គមានអង្គ ៨ នោះ ជាសោភណ-ចេតសិក ៨ ដួង នឹងត្រូវកើតជាមួយចិត្តដែលចម្រើនសតិប្បដ្ឋានទាំង ៨ ឬ ។

ឆ- បើមិនមែនជាលោកុត្តរចិត្ត ចេតសិកដែលជាអង្គមគ្គ ៨ នេះមិនកើតគ្រប់ទាំង ៨ ទេ ។

ស- អ្វីជាមគ្គអង្គដំបូង ក្នុងមគ្គមានអង្គ ៨ ។

ឆ- មគ្គអង្គដំបូង គឺ សម្មាទិដ្ឋិ ការឃើញត្រូវ បើមិនមានការឃើញត្រូវក្នុងនាម និង រូប និង ក្នុងការបដិបត្តិដែលជាការចម្រើនបញ្ញា ក៏ចម្រើនមគ្គអង្គ ៨ មិនបាន សម្មាទិដ្ឋិជាបញ្ញាដែលដឹងលក្ខណៈរបស់នាមធម៌ និង រូបធម៌ ដែលប្រាកដផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។

ក្នុងសំយុត្តនិកាយ មហាវារវគ្គ សុរិយូបមសូត្រទី ១ មានសេចក្តីថា “ ម្នាលភិក្ខុទាំងឡាយ កាលព្រះអាទិត្យនឹងរះឡើង វត្ថុដែលកើតមុន វត្ថុដែលជានិមិត្តមកមុន គឺ ពន្លឺពណ៌មាស យ៉ាងណា វត្ថុដែលជាខាងដើម ជានិមិត្តមកមុននៃការត្រាស់ដឹងអរិយសច្ច ៤ តាមសេចក្តីពិត គឺ សម្មាទិដ្ឋិ ក៏ដូច្នោះដូចគ្នា ។

ភិក្ខុអ្នកមានការឃើញត្រូវនឹងសង្ឃឹមបានថា នឹងដឹងតាមសេចក្តីពិតថា នេះទុក្ខ នេះទុក្ខសមុទ័យ នេះទុក្ខនិរោធ នេះទុក្ខនិរោធគាមិនីបដិ-បទា ។

ម្នាលភិក្ខុទាំងឡាយ ព្រោះដូច្នោះឯង អ្នកទាំងឡាយគប្បីធ្វើសេចក្តីព្យាយាមដើម្បីដឹងតាមសេចក្តីពិតថា នេះទុក្ខ នេះទុក្ខសមុទ័យនេះទុក្ខ-



និរោធ នេះទុក្ខនិរោធគាមិនីបដិបទា ។

យើងគប្បីដឹងនូវបំណងប្រាថ្នាថា តើចម្រើនមគ្គមានអង្គ ៨ ដើម្បីអ្វី តើអ្នកចម្រើនមគ្គមានអង្គ ៨ ដើម្បីអ្វី ។

ស- ចម្រើនមគ្គមានអង្គ ៨ ដើម្បីរំលត់កិលេសគ្រប់ប្រភេទ ដូចជាសេចក្តីក្រោធ ការប្រណៃន សេចក្តីកំណាញ់ ជាដើម រួមសេចក្តីមកថាដើម្បីរំលត់កិលេសគ្រប់យ៉ាង ។

ឆ- មនុស្សដោយច្រើនគិតថា ការចម្រើនវិបស្សនាអាចដោះស្រាយបញ្ហាគ្រប់យ៉ាងឲ្យអស់ទៅបានទាន់ពេល គេគិតថា រំលត់កិលេសបានទាន់ពេល ។ យើងសន្សំកិលេសច្រើនភព ច្រើនជាតិមកហើយ រាប់មិនបាន នឹងរំលត់ឲ្យអស់ភ្លាម ៗ យ៉ាងណាបាន ? បើនៅមិនទាន់ដឹងច្បាស់អរិយសច្ចធម៌ ចំណុចសំខាន់របស់ការចម្រើនវិបស្សនា ដើម្បីដឹងការពិតនូវអ្វីដែលប្រាកដដល់ខ្លួន ដើម្បីកម្ចាត់ការឃើញខុសថា ជាតួខ្លួនដែលនឹងត្រូវប្រឹងប្រែងព្យាយាមអប់រំចម្រើនបញ្ញា ឲ្យកាន់តែច្រើនឡើងតែម្យ៉ាងប៉ុណ្ណោះ ។ សេចក្តីក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ នាវាសូត្រព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងថា ៖

“ ...... ម្នាលភិក្ខុទាំងឡាយ ស្នាមម្រាមដៃ រមែងប្រាកដ ឬស្នាមមេដៃ រមែងប្រាកដដល់ដងកាំបិតរបស់មេជាងឈើ ឬ កូនជាងឈើ តែមេជាង ឬ កូនជាងឈើនោះ មិនអាច ដឹងបានថា ថ្ងៃនេះ ដងកាំបិតរបស់យើងសឹកទៅប្រមាណប៉ុណ្ណេះ បន្តិចទៀតនឹងសឹកទៅប្រមាណប៉ុណ្ណេះ ថ្ងៃមុន ៗ សឹកបានប្រមាណប៉ុណ្ណេះ មេជាង ឬកូនជាងឈើនោះ មានការដឹងត្រឹមតែប៉ុណ្ណេះថា សឹកទៅហើយ សឹកទៅហើយ ដោយពិត យ៉ាងណា ............... ” ។

សេចក្តីឃើញខុសថា ជាតួខ្លួន នឹងធូរស្រាលចុះគ្រប់ពេល ខណៈដែលសតិរលឹកដឹងលក្ខណៈរបស់នាម និង រូប តែយើងមិនដឹងថា នឹងអស់ទៅក្នុងថ្ងៃណាមួយ ។

ស- តែ ប្រសិនបើកំពុងមានសេចក្តីភ្លើតភ្លើន ជាប់ចិត្ត ឬថា កំពុងខឹងក្រោធ សតិនឹងកើតបានយ៉ាងណា ។

ឆ- ខណៈដែលជាលោភមូលចិត្ត ឬ ទោសមូលចិត្តនោះ នឹងមានសតិកើតរួមជាមួយមិនបាន កាលបើអកុសលចិត្តរលត់ទៅ សតិក៏កើតឡើងដឹងថា អកុសលចិត្ត ជានាមធម៌មួយប្រភេទប៉ុណ្ណោះ ។



ស- ចុះបើមិនត្រូវលោភៈ ឬ ទោសៈគ្របសង្កត់ សតិកើតមិនបានឬ

ឆ- បុគ្គលដោយច្រើនគិតយ៉ាងនោះ ព្រោះមិនទាន់យល់ក្នុងរឿងចម្រើនមគ្គមានអង្គ ៨ ខ្ញុំដឹង ចំពោះបុគ្គលខ្លាចលោភៈដែលកើតឡើងរហូតលះបង់សភាវៈដែលកំពុងប្រាកដក្នុងខណៈនោះ គេគិតថា គួរឲ្យចិត្តតាំងមាំក្នុងខ្យល់ដង្ហើម ក្នុងខណៈដែលធ្វើយ៉ាងនោះខ្លះ យ៉ាងនេះខ្លះ ដើម្បីឲ្យមានសតិច្រើន ៗ ក៏ព្រោះការឃើញខុសថា ជាតួខ្លួន អ្នកដែលធ្វើយ៉ាងនោះ គឺ ត្រូវការបង្គាប់បញ្ជាចិត្ត ក្នុងការចម្រើនមគ្គមានអង្គ ៨ ឬន័យម្យ៉ាងទៀត មជ្ឈិមាបដិបទានោះ សតិរលឹកដឹងលក្ខណៈរបស់នាម និង រូប ប្រភេទណាក៏បាន ដែលកំពុងប្រាកដ ជាអកុសលធម៌ក៏បាន ។

អ្នកដែលត្រូវការបង្គាប់បញ្ជាចិត្ត មិនដឹងសភាវធម៌តាមសេចក្តីពិត គេបានត្រឹមតែគិថា សេចក្តីប្រាថ្នានោះ គួរឲ្យស្អប់ខ្ពើម គេមិនដឹងថា ជាលោភៈ បើគ្រាន់តែត្រេកអរ ពេញចិត្តក្នុងវត្ថុដែលស្អាត ៗ និង ក្នុងសំឡេងពីរោះ ៗ ជាដើម លោភៈដ៏ល្អិតជាងការប្រាថ្នាដ៏ខ្លាំងក្លា ក៏ជាទោស ព្រោះបើមិនដឹងលក្ខណៈរបស់លោភៈ ក៏រមែងប្រកាន់ថា ជាតួខ្លួនក្រៃលែងជាងនោះ គេមិនឃើញភាពគួរឲ្យស្អប់ខ្ពើមរបស់មោហមូលចិត្ត

គេមិនដឹងថា ខណៈណាមានមោហៈ ព្រោះមោហៈមិនកើតជាមួយសោ-មនស្សវេទនា និង ទោមនស្សវេទនា តែកើតជាមួយឧបេក្ខាវេទនា គេមិនដឹងថា ខណៈដែលដឹងខ្លួនព្រងើយ ៗ នោះ ជាអកុសលចិត្តទេ យើងគប្បីឃើញទោសរបស់មោហមូលចិត្តផង ខណៈដែលមិនមានសតិនោះ ក៏ជាមោហមូលចិត្តដោយច្រើន ។

មោហៈក្នុងថ្ងៃនេះ ជាបច្ច័យឲ្យកើតមោហៈក្នុងថ្ងៃមុខ យើងនៅតែវង្វេងមិនដឹងលក្ខណៈរបស់សភាវធម៌ ប៉ុន្មានភព ប៉ុន្មានជាតិទៀតហ្ន៎ បើមិនបានចម្រើនវិបស្សនាមិនរលឹកដឹងលក្ខណៈរបស់អកុសលចិត្តដោយចំពោះ ហើយគិតថា គួរស្អប់ខ្ពើមណាស់ ដូចជាចិត្តដែលមានការប្រាថ្នាយ៉ាងខ្លាំងក្លា និង ទោសៈ ជំនួសកន្លែងដែលត្រូវរលឹកដឹងនូវលក្ខណៈរបស់សភាវធម៌ទាំងឡាយនោះ ក៏ត្រឡប់ជាព្យាយាមបង្គាប់បញ្ជា បើយើងព្យាយាមបង្គាប់បញ្ជាសភាវធម៌ ក៏ព្រោះការឃើញខុសថា ជាតួខ្លួន និង មិនមែនជាផ្លូវលះបង់អកុសលធម៌ឲ្យអស់ទៅបាន មជ្ឈិមាបដិបទាមិនមែនជាការបង្គាប់បញ្ជាសភាវធម៌ទេ តែជាការរលឹកដឹងលក្ខណៈរបស់សភាវធម៌ដែលកំពុងប្រាកដ មិនគប្បីខ្វល់ខ្វាយចំពោះសភាវធម៌



ដែលកំពុងប្រាកដ សូម្បីជាអកុសលចិត្តក៏ដោយ ក៏មានការប្រែប្រួលសភាវធម៌ដែលកើតឡើងប្រាកដយ៉ាងណា គប្បីរលឹកដឹងនូវលក្ខណៈរបស់សភាវធម៌នោះ ៗ វិញ ការកង្វល់ក្នុងរឿងលោភៈ និង ទោសៈនោះ គឺ មិនមានប្រយោជន៍ ហេតុអ្វី ក៏មិនរលឹកដឹងក្នុងខណៈនោះថា មានត្រឹមតែនាមធម៌ និង រលឹកដឹងលក្ខណៈរបស់សភាវធម៌ដទៃ ៗ ដែលប្រាកដផង ហើយក៏បានដឹងថា មានសភាវធម៌ច្រើនទៀតណាស់ ដែលនៅមិនទាន់បានរលឹកដឹង យើងដឹងលក្ខណៈរបស់ការដឹងក្នុងសភាពព្រងើយ ៗ ហើយឬនៅ ឬដឹងតែសេចក្ដីត្រេកអរពេញចិត្ត និង សេចក្ដីមិនត្រេកអរវេលាដែលមាន មោហៈ តើបានដឹងខ្លះទេ ។

ស- ខ្ញុំគិតថា ព្រះមានព្រះភាគត្រាស់ឲ្យមានសតិគ្រប់ខណៈដែលមានខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល មែនទេ ។

ឆ- ដរាបណា ខ្យល់ដង្ហើមចូល-ចេញមាន ជីវិតក៏តាំងនៅបាន ការចម្រើនសតិរហូតអស់ជីវិត ការចម្រើនវិបស្សនាមិនចំពោះអារម្មណ៍ណាមួយនោះទេ សតិរលឹកដឹងនាម និង រូបណា ៗ ដែលប្រាកដតាមផ្លូវភ្នែក ត្រចៀក ប្រមុះ អណ្ដាត កាយ ចិត្ត ដើម្បីលះការឃើញខុស

និង សេចក្តីសង្ស័យក្នុងលក្ខណៈរបស់សភាវធម៌ទាំងឡាយ ដែលធ្លាប់ប្រកាន់ថា ជាតួខ្លួន ។

ការចម្រើនវិបស្សនា មិនចំពោះតែខ្យល់ដង្ហើមចូល-ចេញទេ ព្រោះបើជ្រើសរើសអារម្មណ៍ ក៏ព្រោះការឃើញខុសថា មានតួខ្លួន បើពោលដល់ខ្យល់ដង្ហើមចូល-ចេញ ក៏គ្រាន់តែជាការបញ្ញត្តិ តែខណៈដែលកំពុងមានខ្យល់ដង្ហើមនោះ សភាវធម៌ដែលប្រាកដ ក៏ឲ្យដឹងបានក្នុងខណៈនោះ មានលក្ខណៈយ៉ាងណា ៗ សភាពទន់ រឹង ដែលប្រាកដក្នុងខណៈនោះ ជារូបមួយប្រភេទ , សភាពដែលកម្រើក ញ័រ ឬ តឹង ជារូបមួយប្រភេទ , ក្តៅ ត្រជាក់ ក៏ជារូបមួយប្រភេទ ។ សភាវធម៌ទាំងនោះ ជាវត្ថុដែលសតិរលឹកដឹងបាន ប៉ុន្តែនឹងឲ្យសតិរលឹកដឹងលក្ខណៈរបស់សភាវធម៌ណា ៗ បង្គាប់បញ្ជាមិនបាន បើសភាវធម៌ណាដែលប្រាកដ ក៏មិនមានតួខ្លួន ដែលបង្គាប់បញ្ជាឲ្យសតិរលឹកដឹងអារម្មណ៍នេះ ឬ អារម្មណ៍នោះបានឡើយ ។

ស- បើពិចារណារឿងសតិ ដែលរលឹកដឹងលក្ខណៈ របស់នាម និង រូប តាមដែលលោកពោលនោះ ក៏បានយល់ចូលចិត្ត និង ឃើញថា



មិនមានតួខ្លួន តែក៏នៅមិនទាន់ដឹងច្បាស់ គ្រាខ្លះក៏ដឹងថា នៅត្រូវការតួខ្លួនដែលជាអ្នកសម្រេចចិត្ត ដូចជា បើសម្រេចចិត្តថ្ងៃនេះថា នឹងសិក្សាព្រះធម៌វិន័យ និង រក្សាសីល ៥ ហើយឲ្យជឿថា មិនមែនអត្តា តួខ្លួនការសម្រេចចិត្តយ៉ាងនេះ ក៏លំបាកជឿបាន ។

ឆ- បើមិនមែនជាព្រះអរិយបុគ្គល សេចក្តីឃើញខុសថា ជាតួខ្លួនក៏អស់ទៅមិនបាន ព្រោះនៅមានបច្ច័យឲ្យឃើញខុសថា ជាតួខ្លួន ។ ការចម្រើនសតិរលឹកដឹងចំពោះលក្ខណៈរបស់នាម និង រូប ចាំបាច់ត្រូវដឹងច្បាស់ក្នុងសភាវធម៌ទាំងឡាយបន្ថែមទៀត ហើយនឹងដឹងថា សេចក្តីសម្រេចចិត្តយ៉ាងនោះ ក៏ជានាមធម៌មួយប្រភេទ ដែលកើតព្រោះបច្ច័យកាលចម្រើនបញ្ញាកាន់តែចាស់ក្លា រហូតដល់ថ្នាក់ដឹងច្បាស់អរិយសច្ច-ធម៌ ក៏រំលត់សេចក្តីសង្ស័យក្នុងសភាវធម៌ទាំងឡាយ និង ដឹងច្បាស់ថាមិនមានតួខ្លួនយ៉ាងពិតប្រាកដ ។

ការចម្រើនសម្មាមគ្គ គប្បីមានការយល់ចូលចិត្តឲ្យបានត្រឹមត្រូវក្នុងការបដិបត្តិជាដំបូង ប្រសិនបើ ជាដំបូងមានការយល់ឃ្លៀងឃ្លាត ក៏ធ្វើឲ្យមានការបដិបត្តិខុស ហើយលំបាកត្រឡប់មកកាន់ផ្លូវត្រូវទៀតផង ។

បើបដិបត្តិខុសតទៅ ក៏មានតែការឃើញខុសតទៅទៀត មិនដឹងប៉ុន្មានភព ប៉ុន្មានជាតិទេ ។ អ្នកខ្លះពោលថា ត្រូវចាំមើលនាម រូប គេគិតថា មិនមែនជាការឃើញខុស ព្រោះមិនបាននិយាយថា “ តួខ្លួន ” តែការបដិបត្តិដូច្នេះ គឺ បង្ហាញអំពីលក្ខណៈនៃការប្រកាន់យ៉ាងមាំក្នុងតួខ្លួនឯង មានតួខ្លួន ជាអ្នកសម្លឹងមើលការរលឹកដឹង នឹកគិត ។ សូម្បីក្នុងកាលជាដំបូង ក៏មិនគួរនឹងមានការឃើញថា ជាតួខ្លួន ដែលជាអ្នកសម្លឹងមើល ឬ កំណត់ចំពោះអារម្មណ៍ ដូចជាខ្យល់ដង្ហើមចូល-ចេញ ជាដើម ។

សភាវធម៌ទាំងឡាយ ដែលប្រាកដផ្លូវ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ជាសតិប្បដ្ឋានបាន កាលបើមានការចម្រើនសតិរលឹកដឹងលក្ខណៈរបស់សភាវធម៌ផ្សេង ៗ ញយ ៗ រឿយ ៗ ក៏នឹងធ្លាប់ជាមួយសភាវធម៌ទាំងឡាយនោះ និង ដឹងលក្ខណៈដែលផ្សេងគ្នារបស់សភាវធម៌កាន់តែច្បាស់ឡើង ៗ ដោយប្រការដូច្នេះ ទើបឈ្មោះថាជាការ ចម្រើនមគ្គមានអង្គ ៨ ។

---



## អដ្ឋមគ្គ ៨

ស- ការចម្រើនកុសល ជាការសំខាន់ មិនមែនតែក្នុងពេលធ្វើ និង និយាយប៉ុណ្ណោះទេ តែក៏ក្នុងពេលនឹកគិតផង តែការគិតក្នុងវត្ថុដែលល្អជារហូត ប្រព្រឹត្តទៅមិនបានឡើយ ព្រោះយើងសន្សំកិលេសច្រើនមកហើយ បើរលឹកដល់ព្រះពុទ្ធគុណ ក៏ជាកុសលវិតក្ក តែនឹងគិតរឿងតែម្យ៉ាង រឿយ ៗ មិនបាន ហើយមិនឲ្យអកុសលវិតក្កកើត ក៏មិនបាន តើគប្បីបញ្ឈប់អកុសលវិតក្ក យ៉ាងដូចម្តេច ។

ឆ- ពេលរលឹកដល់ព្រះពុទ្ធគុណ និង បានជ្រាបក្នុងព្រះមហាករុណាគុណ ដែលទ្រង់សម្តែងធម៌ដល់សត្វលោក ក៏ជាបច្ច័យឲ្យកើតកុសលវិតក្ក យើងអាចនឹងទៅនមស្ការសំវេជនីយដ្ឋាន បានដល់ ស្ថានទីប្រសូត ស្ថានទីទ្រង់ត្រាស់ដឹង ស្ថានទីដែលទ្រង់សម្តែងធម្មទេសនា និង ស្ថានទីដែលទ្រង់រំលត់ខន្ធបរិនិព្វាន ការនមស្ការសំវេជនីយដ្ឋាន គឺជាការបង្ហាញនូវសទ្ធាក្នុងព្រះធម៌ និង ការរលឹកដល់គុណរបស់ព្រះធម៌ សូម្បីមានការកន្លងទៅជាង ២.៥០០ ឆ្នាំហើយ ក៏នៅមានប្រយោជន៍ដ៏សម្បូរដល់យើងបានក្នុងពេលនេះ សំវេជនីយដ្ឋានជាស់តឿនឲ្យយើងមិនភ្លេច

អំពីការចម្រើនសតិ ដែលជាបច្ច័យឲ្យកើតកុសលចិត្តដ៏ច្រើនសន្ទឹក-សន្ធាប់តែម្យ៉ាង ។

ខណៈដែលកុសលចិត្តកើតឡើង ក៏លះបង់អកុសលវិតក្កបានដោយគ្រា ៗ មិនរំលត់អស់ជាសមុច្ឆេទទេ តែការចម្រើនមគ្គអង្គ ៨ ដែលជាការចម្រើនវិបស្សនាប៉ុណ្ណោះ ដែលលះអកុសលវិតក្កអស់ជាសមុច្ឆេទបានក្នុងទីបំផុត ។ កាលចម្រើនវិបស្សនា អកុសលចិត្តកើតឡើង ក៏មិនត្រូវបង្គាប់បញ្ជា ព្រោះអកុសលវិតក្កបានកើតឡើងហើយ អកុសល-វិតក្ក ជាសភាវធម៌មួយប្រភេទ ដែលគួររលឹកដឹងលក្ខណៈ ក្នុងមហា-សតិប្បដ្ឋាន សភាវធម៌គ្រប់ប្រភេទ ជាសតិប្បដ្ឋាន ។ បើដឹងថា មិនមានសភាវធម៌ណាមិនមែនជាសតិប្បដ្ឋាន ក៏នឹងផ្ដើមដឹងថា សភាវធម៌ទាំង-ឡាយនោះ ក៏មានត្រឹមតែនាមធម៌ និង រូបធម៌ប៉ុណ្ណោះ ដូច្នោះ កាលបើអកុសលវិតក្កកើតឡើង ហេតុអ្វីមិនរលឹកដឹងថា ត្រឹមតែនាមធម៌មួយប្រភេទ , កាលដឹងលក្ខណៈរបស់អកុសលវិតក្កច្បាស់ឡើង ក៏នឹងធ្វើឲ្យស្រាលស្ដើងនូវការប្រកាន់មាំថា ជាតួខ្លួន ប៉ុន្តែបើមិនមែនជាព្រះអរ-ហន្ត អកុសលធម៌ក៏នៅតែកើតឡើង , អកុសលធម៌នឹងរលត់អស់ជា



សមុច្ឆេទ គឺ កាលដែលបានសម្រេចជាព្រះអរហន្តប៉ុណ្ណោះ ។

ស- បានដឹងថា សម្មាសង្កប្បៈ ការត្រិះរិះត្រូវ ជាអង្គមគ្គមួយក្នុងមគ្គមានអង្គ ៨ , សម្មាសង្កប្បៈ គិតរឿងនាមរូបដូចម្ដេច ?

ឆ- សម្មាសង្កប្បៈ ជាចេតសិកធម៌មួយប្រភេទ បានដល់ វិតក្ក-ចេតសិក លក្ខណៈរបស់វិតក្កចេតសិក មិនដូចដែលយើងប្រើពាក្យថា “ គិត ” នោះទេ ក្នុងវិសុទ្ធិមគ្គ “ បឋវីកសិណនិទ្ទេស ” សម្ដែងលក្ខណៈរបស់វិតក្កចេតសិក ដូច្នេះ “ វិតក្កនោះមានការប្រត់ចុះនូវចិត្តក្នុងអារម្មណ៍ជាលក្ខណៈ មានការប៉ះខ្ទប់ជាមុន និង ប៉ះខ្ទប់ដោយទូទៅជាកិច្ច .......... មានការនាំចិត្តទៅកាន់អារម្មណ៍ជាអាការប្រាកដ ” ។

វិតក្ក ដែលជាសម្មាសង្កប្បៈក្នុងមគ្គមានអង្គ ៨ កើតព្រមជាមួយនឹងសម្មាទិដ្ឋិ និង សម្មាសតិ , សម្មាសង្កប្បៈ កើតជាមួយចិត្ត ដែលរលឹកដឹងលក្ខណៈរបស់នាម និង រូប ដែលប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត , យើងដឹងថា វិតក្កនាំចិត្តឆ្ពោះកាន់អារម្មណ៍ សម្មាសង្កប្បៈក្នុងមគ្គមានអង្គ ៨ នាំចិត្តឆ្ពោះកាន់នាមធម៌ និង រូបធម៌ដែលជាអារម្មណ៍ ក្នុងខណៈនោះ វិតក្កចេតសិកក៏កើតរួមជាមួយចិត្ត

និង រលត់ជាមួយចិត្ត សម្មាសង្កប្បៈកើតរួមជាមួយចិត្តដែលដឹងលក្ខណៈរបស់នាមធម៌ និង រូបធម៌ , ការដឹងលក្ខណៈរបស់អារម្មណ៍ដែលប្រាកដមិនដូចគ្នានឹងការគិតរឿងសភាវធម៌ ដែលរលត់ទៅហើយនោះទេ សម្មា-សង្កប្បៈ លះមិច្ឆាសង្កប្បៈ ដែលជាការត្រិះរិះខុស ។

ស- សម្មាសង្កប្បៈ លះមិច្ឆាសង្កប្បៈ ដូចម្តេច ?

ឆ- សម្មាសង្កប្បៈក្នុងមគ្គមានអង្គ ៨ កើតជាមួយចិត្ត ដែលរលឹកដឹងលក្ខណៈរបស់នាម និង រូប ខណៈនោះមិនមានការត្រិះរិះខុស តែការត្រិះរិះខុសនៅកើតឡើងបានទៀត លុះត្រាតែចម្រើនមគ្គមានអង្គ ៨ តទៅទៀត មិច្ឆាសង្កប្បៈក៏ត្រូវរលត់អស់ក្នុងទីបំផុត ។

ស- បានឮអ្នកខ្លះនិយាយថា ពេលចម្រើនសតិប្បដ្ឋានមិនគួរគិត អ្វី គួរព្យាយាមសម្លឹងមើលតែសភាវធម៌ ដែលប្រាកដក្នុងខណៈនោះ ការប្រតិបត្តិយ៉ាងនោះ លះបង់មិច្ឆាសង្កប្បៈបានទេ ?

ឆ- ពេលព្យាយាមមិនឲ្យគិតនោះ មិនមែនការចម្រើនមគ្គមានអង្គ ៨ តើហាមការគិតយ៉ាងដូចម្តេច ? ក្នុងជីវិតនេះ ក៏មានអារម្មណ៍ផ្សេងៗ ដែលប្រាកដផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត , ការគិត



ក៏ជាសភាវធម៌ម្យ៉ាង ហេតុអ្វីមិនរលឹកដឹងថា ជានាមធម៌មួយប្រភេទ បើមិនរលឹកដឹង ក៏រមែងឃើញខុសថា ជាតួខ្លួនអ្នកគិត និង តួខ្លួនជាអ្នកព្យាយាមមិនឲ្យគិត ។

ពេលដែលគិតថា គួរធ្វើយ៉ាងនេះ យ៉ាងនោះ ជាមួយនឹងការគិត ក៏គឺ ការប្រកាន់មាំក្នុងការឃើញខុសថា ជាតួខ្លួន , ខណៈព្យាយាមធ្វើអ្វីមួយក្នុងការគិត ការគិតនោះក៏រលត់ទៅហើយ ដូច្នោះ ទើបជាការប្រកាន់មាំក្នុងវត្ថុដែលរលត់ទៅហើយនោះឯង ។

ខណៈណា ដែលរលឹកដឹងលក្ខណៈនាម ឬ រូប ក៏មិនមានតួខ្លួនជាអ្នកព្យាយាមឲ្យគិត ឬ ដែលកំពុងមើលនាមរូប ដែលនិយាយថា មិនបានគិតថា ជាតួខ្លួន ត្រឹមតែមើលព្រងើយ ៗ ក៏ត្រូវហើយនោះទេ តែដែល កំពុងព្យាយាមកំណត់នោះ សូម្បីត្រឹមតែសម្លឹងមើលព្រងើយ ៗ ក៏បានសម្តែងហើយថា មិនមែនជាការចម្រើនមគ្គមានអង្គ ៨ ឡើយ ។

ស- បានជ្រាបថា មគ្គមានអង្គ ៨ នោះ អង្គខ្លះ ក៏ជាចំណែកនៃសីល អង្គខ្លះជាចំណែកនៃសមាធិ និង អង្គខ្លះជាចំណែកនៃបញ្ញា , សម្មាទិដ្ឋិ និង សម្មាសង្កប្បៈ ជាចំណែកបញ្ញា ហេតុអ្វីបានជាដូច្នេះ ។

ច- សម្មាទិដ្ឋិ ដឹងច្បាស់ក្នុងលក្ខណៈរបស់នាមរូប ដែលប្រាកដ ក្នុងខណៈនោះ , សម្មាសង្កប្បៈ នាំចិត្តឆ្ពោះកាន់អារម្មណ៍ ដើម្បីឲ្យសម្មាទិដ្ឋិដឹងច្បាស់ក្នុងអារម្មណ៍នោះ ព្រោះសម្មាសង្កប្បៈ នាំចិត្តឆ្ពោះទៅកាន់ អារម្មណ៍ ក្នុងផ្លូវដែលត្រូវ ដូច្នោះ ទើបជាចំណែកបញ្ញាក្នុងមគ្គមាន អង្គ ៨ ។

ស- បានជ្រាបថា សម្មាវាចា សម្មាកម្មន្តៈ និង សម្មាអាជីវៈ ទាំង ៣ នេះ ជាចំណែកសីលក្នុងមគ្គមានអង្គ ៨ នោះ យ៉ាងណា ?

ច- មានអកុសលសីល និង កុសលសីល ការធ្វើផ្លូវកាយ-វាចា ជាសីល , កុសលសីលនោះ បានដល់ សីល ៥ ជាដើម ដែលជាការលះ បង់កាយទុច្ចរិត និងវចីទុច្ចរិត , កាយទុច្ចរិត បានដល់ ការសម្លាប់ ការ កាន់យករបស់អ្នកដទៃមកជារបស់ខ្លួន ការប្រព្រឹត្តិខុសក្នុងកាម , វចីទុច្ចរិត បានដល់ មុសាវាទ បិសុណាវាទ ផរុសវាទ និងសម្ផប្បលាបវាទ។

ស- ខណៈដែលវៀរចាកវចីទុច្ចរិត និង កាយទុច្ចរិតនោះ ជាសម្មាវាចា និង សម្មាកម្មន្តៈក្នុងមគ្គមានអង្គ ៨ ឬទេ ?

ច- សូមកុំភ្លេចថា សម្មាទិដ្ឋិ ដែលជាអង្គមួយរបស់មគ្គមានអង្គ ៨



នោះ ដឹងលក្ខណៈរបស់នាមរូប ដែលប្រាកដតាមផ្លូវ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត , យើងអាចវៀរចាកវចីទុច្ចរិត និង កាយទុច្ចរិត ដោយមិនរលឹកដឹងលក្ខណៈរបស់នាមរូបទេ បើដូច្នោះ សម្មាទិដ្ឋិ និងសម្មាសតិ ក្នុងមគ្គមានអង្គ ៨ ក៏មិនកើតរួមជាមួយចិត្តក្នុងខណៈនោះ ដូច្នោះ ទើបមិនមែនជាសម្មាវាចា និង សម្មាកម្មន្តៈ ដែលជាអង្គរបស់ មគ្គមានអង្គ ៨ ខណៈនោះ ក៏ជាកុសល តែមិនមែនជាកុសលប្រភេទ មគ្គមានអង្គ ៨ ទេ ។

ស- តើវៀរចាកវចីទុច្ចរិត ដូចម្ដេច ពេលនៅជាមួយអ្នកដទៃ ដែលពោលវចីទុច្ចរិត ហើយយើងក៏និយាយជាមួយនឹងគេដែរ ។

ច- បើមិនមែនជាព្រះអរហន្ត ក៏តែងតែមានវចីទុច្ចរិត តែព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែង ជាបច្ច័យធ្វើឲ្យស្រោលស្ដើង បាន ពេលចង់និយាយដល់អ្នកដទៃក្នុងផ្លូវមិនគួរស្ដាប់ ឬ ពេលដែល គេបានត្អូញត្អែរក្នុងវត្ថុមិនគួរត្រេកអរពេញចិត្ត ដែលកើតឡើងក្នុងជីវិត យើងក៏បណ្ដោយតាមគេ តែបើបានសិក្សាព្រះធម៌ ក៏បានដឹងថា ខណៈ ណា ជាអកុសលចិត្ត និងដឹងទោសភ័យរបស់អកុសល កាលដឹងវិធី

ចម្រើនសតិប្បដ្ឋាន ក៏ជាបច្ច័យឲ្យវៀរចាកវចីទុច្ចរិតជំនួសកន្លែងដែលកើតអកុសលចិត្ត ហើយក៏អាចនឹងកើតសេចក្តីករុណាដល់អ្នកដែលពោលវចីទុច្ចរិត និង រមែងជួយឲ្យអ្នកដទៃបានកើតកុសលចិត្ត ជំនួសអកុសលចិត្តទៀតផង កាលរលឹកដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ ក្នុងខណៈ ដែលវៀរចាកវចីទុច្ចរិត ក៏ជាសម្មាវាចាក្នុងមគ្គមានអង្គ ៨ , ចិត្តដែលរលឹកដឹងនោះ ជាចិត្តដែលមានសម្មាទិដ្ឋិ និង សម្មាសតិ ដែលជាមគ្គមានអង្គ ៨ កើតរួមជាមួយ ។

ស- យើងអាចដឹងយ៉ាងនេះ តាមបរិយត្តិ តែចំពោះការបដិបត្តិនោះសែនលំបាកណាស់ ខ្ញុំនិយាយវចីទុច្ចរិតរួចទៅហើយ ទើបដឹងខ្លួន ។

ឆ- អ្នកនឹងដឹងខ្លួនឯងថា ពេលចម្រើនសតិហើយ បច្ច័យដែលនឹងឲ្យកើតវចីទុច្ចរិត ក៏មានការថយចុះ និស្ស័យ និង ការសន្សំ ក៏ផ្លាស់ប្តូរទៅបាន តែមិនមែនតួខ្លួនជាអ្នកផ្លាស់ប្តូរនិស្ស័យ និង ការសន្សំទេ ការចូលចិត្តក្នុងព្រះធម៌ និង ការបដិបត្តិធម៌ ជាបច្ច័យធ្វើឲ្យផ្លាស់ប្តូរ យើងពិចារណាបានដោយខ្លួនឯងថា ព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែង ជាសច្ចធម៌ ហើយសទ្ធាក្នុងព្រះធម៌ ក៏តាំងមាំឡើង ។



ស- លើកតួយ៉ាង សម្មាកម្មន្តៈ ការងារត្រូវ មកបង្ហាញបានទេ ។

ឆ- ពេលដែលទៀបនឹងសម្លាប់សត្វដែលទិច ឬ ខាំយើង យើងក៏យកដៃគ្រវាសចេញទៅស្រាល ៗ នេះជាការវៀរចាកការសម្លាប់សត្វ ហើយក៏ជាសីល តែបើដឹងលក្ខណៈរបស់នាមធម៌ និង រូបធម៌ ដែលប្រាកដក្នុងខណៈនោះ ក៏ជាសម្មាកម្មន្តៈក្នុងមគ្គមានអង្គ ៨ ។

ស- មានគេប្រាប់ថា គេមិនសម្លាប់ មិនបាន ពេលត្រូវមូសខាំ ឬ សត្វល្អិតទិច គេក៏សម្លាប់ភ្លាម ។

ឆ- ការចម្រើនសតិ ជាបច្ច័យធ្វើឲ្យកើតកុសលចិត្តរឿយ ៗ កុសលចិត្តកើតរួមជាមួយទោសៈមិនបាន កុសលចិត្តតែងកើតរួមជាមួយ អទោសៈ , អទោសៈ គឺ មេត្តា ។ យើងអាចដឹងបានថា កាលបើចម្រើនសតិហើយ សេចក្តីមេត្តា ករុណា នឹងកើតឡើងរឿយ ៗ យើងនឹងគិតដល់សេចក្តីសុខរបស់សត្វ-បុគ្គលដទៃកាន់តែច្រើន យើងគួរធ្វើឲ្យមូស ឬ សត្វល្អិតដល់នូវសេចក្តីទុក្ខ ឬផ្តាច់ជីវិតដែរឬទេ ? កាលបើចម្រើនសតិ ក៏ដឹងថា នឹងធ្វើ និយាយ គិត ក្នុងផ្លូវផ្សេង ៗ ដែលជាកុសលបាន យ៉ាងណា ហើយក៏បានឃើញគុណតម្លៃនៃការចម្រើនសតិក្នុងជីវិតប្រចាំ

ថ្ងៃ ។

ស- សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ គឺយ៉ាងណា ?

ឆ- ចេតសិកដួងនេះ ធ្វើឲ្យវៀរចាកការចិញ្ចឹមជីវិតក្នុងផ្លូវទុច្ចរិត សម្មាអាជីវៈ ដែលជាមគ្គអង្គ ៨ នឹងត្រូវកើតរួមជាមួយសម្មាទិដ្ឋិ ខណៈដែលវៀរចាកការចិញ្ចឹមជីវិតក្នុងផ្លូវទុច្ចរិត ហើយសតិរលឹកដឹងលក្ខណៈនាមរូបនោះ ក៏ដឹងថា មិនមែនតួខ្លួនអ្នកវៀរ ។

ស- ដឹងថា សម្មាអាជីវៈ ជាសភាវធម៌ដូចនឹងសម្មាវាចា និង សម្មាកម្មន្តៈ ឬ ផ្សេងគ្នាយ៉ាងណា ។

ឆ- អ្នកខ្លះ ក៏វៀរចាកទុច្ចរិតកម្មក្នុងការចិញ្ចឹមជីវិតមិនបាន ហើយក៏មិនមានផ្លូវដទៃទៀត ក្រៅពីអាជីពសម្លាប់មាន់ ដើម្បីចិញ្ចឹមជីវិតខ្លួននិងក្រុមគ្រួសារ គេត្រូវសម្លាប់មាន់រាល់ថ្ងៃ ហើយគេធ្វើទានដើម្បីលាងបាប ព្រោះការសម្លាប់ នឹងសងគ្នាបានយ៉ាងណា ។

ឆ- យើងធ្វើកម្មល្អ សងនឹងកម្មអាក្រក់មិនបាន ស្រេចហើយលើកម្មឲ្យផល តាមសមគួរដល់កម្មនោះ ៗ ការសម្លាប់ជាអកុសលកម្មធ្វើឲ្យកើតក្នុងអបាយភូមិបាន សូម្បីបានធ្វើកម្មល្អក៏ដោយ ។



ស- តែអ្នកនោះ រកផ្លូវចិញ្ចឹមជីវិតដទៃមិនបាន គេធ្លាប់រករបរដទៃទៀតដែរ តែរកប្រាក់មិនល្មមនឹងចិញ្ចឹមគ្រួសារ អ្នកខ្លះមិនមានផ្លូវផ្សេងទៀតឡើយ គេចាំបាច់ត្រូវធ្វើទុច្ចរិតកម្មដើម្បីចិញ្ចឹមជីវិត ។

ឆ- មិនមានអ្វីដែលកើតឡើងគ្មានហេតុ-បច្ច័យទេ កិលេសដែលបានសន្សំមកហើយ ធ្វើឲ្យមានការចិញ្ចឹមជីវិត ជាអ្នកលក់សាច់ ជួញដូរអាវុធ ជួញទឹកស្រវឹងជាដើម អាជីពទាំងនោះ ជាមិច្ឆាជីព ជាបច្ច័យឲ្យកើតអកុសលកម្ម ថ្ងៃណាមួយ សតិនឹងធ្វើឲ្យផ្លាស់ប្តូរពីមិច្ឆាជីពបាន មនុស្សជោយច្រើនអាចគិតថា ផ្លាស់ប្តូរអាជីពមិនបាន តែបើមានសតិនិង បញ្ញា ក៏នឹងមានបច្ច័យធ្វើឲ្យមានការចិញ្ចឹមជីវិត ដោយមិនប្រកបជាមួយអកុសលកម្ម ។

ស- អ្នកដែលមិនបានជួញដូរ ដូចពោលមកហើយ តែក៏ជាមនុស្សដែលជាប់រវល់ “ ក្នុងវង្វង់ធុរកិច្ច ” នោះ ខ្ញុំគិតថា ដែលនឹងឲ្យបានកម្រៃនោះ ក៏គង់នឹងនិយាយការពិតជារឿយ ៗ មិនបាន , អ្នកធុរកិច្ចគួរផ្លាស់ប្តូរអាជីព ឲ្យជាការចិញ្ចឹមជីវិតដែលបរិសុទ្ធបានទេ , ខ្ញុំបានដឹងចំពោះមនុស្សម្នាក់ជាដំបូង ក៏ជាអ្នករស់នៅក្នុងវង្វង់ធុរកិច្ច តែក៏ផ្លាស់ប្តូរ

អាជីព ម្តងនេះ គេជាអ្នកបោះពុម្ពសៀវភៅ ព្រោះគេយល់ថា អាជីពនេះ មានឱកាសបម្រើប្រជាជនបានល្អជាង ។

ឆ- បញ្ហាដែលថា អ្នកណានឹងចិញ្ចឹមជីវិតបរិសុទ្ធបាន ឬ មិនបាន រមែងសម្រេចលើបុគ្គលនោះ , បុគ្គលក្នុងវង្វង់ធុរកិច្ច នឹងអាចធ្វើអកុ-សលកម្មបាន ដូចជា ក្នុងខណៈដែលមិនស្មោះត្រង់ និងធ្វើឲ្យអ្នកដទៃក្តៅក្រហាយ ព្រោះការស្វែងរកកម្រៃជាដើម តែគេក៏មានកុសលចិត្តបាន គេអាចនឹងវៀរចាកមុសាវាទ សូម្បីនឹងដឹងថា ការងារដែលធ្វើបានកម្រៃតិចតួច បើគេរលឹកដឹងលក្ខណៈរបស់នាមរូប ក្នុងខណៈដែលវៀរចាកមុសាវាទនោះ ក៏ជាសម្មាអាជីវៈ ក្នុងមគ្គមានអង្គ ៨ ។

ស- អ្នកដែលមានអាជីពជាទាហាន មានសម្មាអាជីវៈ បានឬទេ ? ។

ឆ- គេមានអកុសលចិត្ត និង កុសលចិត្តបាន ក្នុងខណៈផ្សេងគ្នា ខណៈដែលសម្លាប់ គឺ ជាអកុសលកម្ម តែគេក៏ធ្វើកុសលកម្មបានដូចគ្នា ។ ក្នុងខុទ្ទកនិកាយ សុត្តនិបាត មង្គលសូត្រ ដែលពោលពីឧត្តមមង្គល ឧត្តមមង្គលប្រការខ្លះ គឺ “ ការទំនុកបម្រុងមាតាបិតា ការសង្គ្រោះបុត្ត



កិរិយា ការងារមិនច្របូកច្របល់ នេះជាឧត្តមមង្គល ” ។

ទាហាន ក៏ចម្រើនកុសលបាន និង ក៏គួរចម្រើនកុសលផងដែរ ក្នុងអង្គុត្តរនិកាយ បញ្ចកនិបាត សុមនវគ្គទី ៤ សីហសូត្រ ពោលអំពី សីហសេនាបតី ដែលជាសាវករបស់ព្រះមានព្រះភាគ ។

ស- អ្នកដែលមានអាជីពជាអ្នករាជការ នឹងមានបច្ច័យក្នុងការចិញ្ចឹមជីវិតបានបរិសុទ្ធជាងអាជីពដទៃ ព្រោះមិនមានការគិតរឿងស្វែងរកកម្រៃផ្សេង ៗ ទៀត ។

ឆ- គេអាចមានកុសលចិត្តច្រើនក៏បាន អាចប្រកាន់ខ្លួន អាចគិតដល់ការសម្រេចរបស់ខ្លួនឯង ទាំងនេះក៏សម្រេចលើហេតុ-បច្ច័យទាំង-អស់ បើហេតុ-បច្ច័យសន្សំមកឲ្យមានអាជីពនោះ អាជីពនោះជាជីវិតប្រចាំថ្ងៃ កាលចម្រើនសតិ ក៏ជាបច្ច័យឲ្យធ្វើកិច្ចការងារ ដែលប្រកបដោយកុសលចិត្តច្រើន ៗ ។ បើយើងជួយឲ្យអ្នកដទៃយល់ចូលចិត្តក្នុងធម៌ ក៏ដូចជាជួយសង្គមក្នុងផ្លូវដ៏ល្អ និង ជួយឲ្យលោកមានសេចក្តីស្ងប់សុខផង ។

ស- ប៉ុន្តែថា អ្នកដែលគិតតែរឿងប្រាក់រាល់ថ្ងៃ នឹងមានសតិរលឹក

ដឹងលក្ខណៈរបស់នាមរូប យ៉ាងណា ។

ធ- មួយថ្ងៃ ៗ តើលោកចាប់កាន់ប្រាក់ឬ ?

ស- គ្រប់គ្នាទទួលកាន់ នេះជាធម្មតារបស់ជីវិត

ធ- ពេលឃើញប្រាក់ មិនគួរចម្រើនសតិឬ លោកគិតថា អ្វីខ្លះដែលមិនមែនជាសតិប្បដ្ឋាន ។

ស- ពេលមើលប្រាក់ ក៏ឃើញពណ៌ ពេលប៉ះខ្ចប់ ក៏មានលក្ខណៈទន់ ឬ រឹង តែបើរលឹកដឹងត្រឹមតែលក្ខណៈប៉ុណ្ណោះ មិនដឹងថា ជាក្រដាសប្រភេទណា មិនយូរប៉ុន្មាន ក៏ជាអ្នកក្រលំបាក ។ ខ្ញុំជឿហើយថា ការចម្រើនសតិប្បដ្ឋានមានប្រយោជន៍ច្រើន តែក៏នៅប្រកាន់ថា ជាចំណែកមួយផ្សេងអំពីជីវិត ខ្ញុំគិតថា ដំណើរជីវិតមានពីរផ្លូវ គឺ ជីវិតដែលចម្រើនសតិប្បដ្ឋានជាចំណែកធំ ពេលដែលខ្ញុំនៅផ្ទះម្នាក់ឯង និង ជីវិតដែលជាផ្នែកធ្វើការងារ ។

ធ- លោកមានគិតទេថា ព្រះមានព្រះភាគទ្រង់ត្រាស់ថា មានខណៈណាខ្លះដែលមិនគួរចម្រើនសតិ ។

ស- តែចម្រើនសតិរឿយ ៗ មិនបាន ដូចជាពេលដែលកំពុង



បង្វិលបើកសោទូដែកក្នុងកន្លែងធ្វើការងារជាដើម ក៏ត្រូវគិតដល់លេខបើក ប្រសិនបើដឹងត្រឹមតែសភាពរឹង ញ៉រ ឬពណ៌ ចោរក៏នឹងចូលមកយកប្រាក់អស់ខ្ញុំគិតថា ខណៈដែលគិតនោះ ចម្រើនសតិប្បដ្ឋានមិនបាន។

ធ- ក្នុងករណីនេះ ក៏នៅតែជាតួខ្លួនអ្នកគិត ហេតុអ្វីចម្រើនសតិប្បដ្ឋានមិនបាន ក្នុងខណៈដែលបានដឹងថា ជាក្រដាសប្រភេទណា និងក្នុងខណៈគិតដល់លេខបើករបស់សោទ្វារ តើអ្វីដែលមិនមែនជានាមធម៌រូបធម៌ ខ្ញុំយល់ថា លោកត្រូវធ្វើការងារ តែលោកបានគិតទេថា ខណៈនោះ មិនអាចចម្រើនសតិប្បដ្ឋានបានទេឬ ។

ព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់សម្ដែង អាចបដិបត្តិតាមបានពិត ៗ ក្នុងអង្គុត្តរនិកាយ អដ្ឋកនិបាត ទីឃជាណុសូត្រ ព្រះមានព្រះភាគទ្រង់សម្ដែងធម៌ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខក្នុងបច្ចុប្បន្ន និង ក្នុងខាងមុខដល់កុលបុត្ត ធម៌ប្រការមួយ គឺ អារក្ខសម្បទា មានសេចក្ដីក្នុងព្រះសូត្រថា “ ម្នាលព្យគ្ឃបជ្ជៈ អារក្ខសម្បទា ដូចម្ដេច កុលបុត្តក្នុងលោកនេះ ភោគទ្រព្យដែលបានមកដោយការប្រឹងប្រែងព្យាយាម សន្សំដោយកម្លាំងខ្លួន បែកញើសហូរញើស ប្រកបដោយធម៌

បានមកដោយធម៌ គេថែរក្សាទុកដាក់ភោគទ្រព្យទាំងឡាយនោះយ៉ាងល្អ ដោយធ្វើទុកក្នុងចិត្តថា ដូចម្តេច ព្រះរាជាមិនរឹបអូសភោគទ្រព្យទាំងនេះរបស់យើង , ចោរដូចម្តេច មិនលួចយក , ដូចម្តេច ភ្លើងមិនឆេះ , ទឹកមិនបន្សាត់នាំទៅ , ទាយាទដែលមិនជាទីស្រឡាញ់ មិនលួចយកទៅ ។ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា អារក្ខសម្បទា ។ ” ព្រះមាន-ព្រះភាគ ព្រះអង្គមិនបានទូន្មានក្នុងវត្ថុដែលបដិបត្តិមិនបាននោះទេ ។

គួរចម្រើនសតិរលឹកដឹងមិនចំពោះតែអារម្មណ៍ដែល ប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ប៉ុណ្ណោះទេ តែក៏ត្រូវរលឹកដឹងអារម្មណ៍ផ្លូវចិត្តផង ព្រោះថា មិនឲ្យដឹងក្រដាសប្រាក់ប្រភេទណាក៏មិន បាន ការពិតយ៉ាងដូច្នោះឬ ?

ស- មិនឲ្យដឹងដូច្នោះ ទេឬ ?

ឆ- វត្ថុគ្រប់យ៉ាង ជាសតិប្បដ្ឋានបានទាំងអស់ បុគ្គលខ្លះយកវេលាពេលថ្ងៃ ឲ្យដឹងចំពោះនាមខ្លះ រូបខ្លះ ដូចជា ការឃើញ ការបានឮប៉ុណ្ណោះជាដើម គេគិតថា ដែលដឹងថា អារម្មណ៍នោះជាអ្វី ដូចជាដឹងថាក្រដាសប្រាក់ប្រភេទណា ដឹងថា ភ្លើងចរាចរពណ៌ខៀវ ឬ ពណ៌ក្រហម



នោះគឺ មិនមែនជាសតិប្បដ្ឋានឬ លោកមិនគិតទេឬថា ការបដិបត្តិយ៉ាងនោះ ខុសប្រក្រតី , ខ្ញុំបានជ្រាបថា អ្នកខ្លះនិយាយថា ពេលគេចម្រើនវិបស្សនា គេចំណាំដល់ពួកមិត្ត មាតាបិតាមិនបាន បើចម្រើនវិបស្សនាហើយចាំអ្វីមិនបាន ក៏មានន័យថា ការចម្រើនវិបស្សនាក្នុងខណៈដែលធ្វើកិច្ចការងារតាមប្រក្រតីប្រចាំថ្ងៃមិនបាន , បើគេបើករថយន្ត និងចម្រើនវិបស្សនា គេក៏មិនដឹងថា ខណៈណាជាភ្លើងចរាចរ ជាភ្លើងពណ៌-ខៀវខណៈណាជាភ្លើងពណ៌ក្រហម ។ ការបដិបត្តិរបៀបនេះ មិនមែនជាសម្មាមគ្គ , ការចម្រើនមគ្គមានអង្គ ៨ ជាការចម្រើនសម្មាទិដ្ឋិ ការឃើញត្រូវក្នុងសភាវធម៌ទាំងឡាយក្នុងជីវិតប្រចាំថ្ងៃ ។

ស- ខ្ញុំនៅមិនទាន់យល់ថា ខណៈចម្រើនវិបស្សនានោះ គឺ ដំណើរជីវិតជាប្រក្រតីប្រចាំថ្ងៃ ព្រោះបានដឹងថា ខណៈចម្រើនវិបស្សនា ក៏ហាមផឹកស្រា ។

ឆ- នឹងហាមអ្នកដទៃមិនឲ្យផឹកស្រាបានយ៉ាងណា ព្រោះសតិទេតើដែលធ្វើការបញ្ឈប់ការផឹកស្រា និងធ្វើឲ្យស្រាលស្តើង ។ ព្រះអរិយ-បុគ្គលប៉ុណ្ណោះ ដែលរក្សាសីល ៥ បានដោយបរិបូរណ៍ , បុថុជ្ជនរមែង

កន្លងសីលបាន បើមានហេតុបច្ច័យ ដូចជា កាលបើមានហេតុបច្ច័យ យើងក៏អាចនឹងសម្លាប់ ដើម្បីការពារខ្លួនក៏បាន ។

ជាការពិត មិនចំពោះតែការសិក្សាធម៌ប៉ុណ្ណោះទេ តែថា កុសលគ្រប់ប្រការ គឺជាគ្រឿងឧបការៈដល់ការចម្រើនវិបស្សនា និង ម្យ៉ាងទៀត កាលចម្រើនសតិញយៗ រឿយ ៗ ក៏ជាបច្ច័យឲ្យធ្វើកុសលផ្សេង ៗ រួមទាំងការរក្សាសីលផង កាលដឹងផ្លូវចម្រើនសតិប្បដ្ឋានហើយ ក៏រមែងនឹងផ្លាស់ប្តូរដំណើរជីវិត និង វៀរចាកនូវទុច្ចរិតកម្មនោះ ៗ ផង ។

ស- បើដូច្នោះ សតិប្បដ្ឋានក៏មានផល ដែលខ្ញុំសូមហៅថា បាដិហារិយ៍ ដែលធ្វើឲ្យមានការផ្លាស់ប្តូរឧបនិស្ស័យបាន បានទេ ?

ធ- មនុស្សយើង លំបាកកែឧបនិស្ស័យណាស់ មិនដឹងនឹងកែបានយ៉ាងណា លោកប្រាថ្នាចង់កែឧបនិស្ស័យឲ្យបានល្អ មែនទេ មានផ្លូវណាខ្លះ , វត្ថុគ្រប់យ៉ាង កើតឡើងព្រោះហេតុបច្ច័យ , បច្ច័យដែលធ្វើឲ្យឧបនិស្ស័យអាក្រក់ផ្លាស់ប្តូរបានច្រើននោះ ក៏គឺការចម្រើនវិបស្សនា ការឃើញត្រូវក្នុងសភាវធម៌តាមសេចក្តីពិត ។ បុគ្គលគ្រប់រូប នឹងដឹងដោយខ្លួនឯងថា កាលចម្រើនមគ្គមានអង្គ ៨ ឧបនិស្ស័យនឹងថយចុះទៅ ៗ



និង មានការប្រែប្រួលជាលំដាប់ សូម្បីនៅមិនទាន់បានសម្រេចអរិយសច្ចធម៌ ក៏ដោយ ។

## សម្មាវាយាមោ

ស- សតិកើតឡើង ព្រោះអាស្រ័យហេតុបច្ច័យ យើងបង្គាប់បញ្ជាឲ្យសតិកើតមិនបាន សតិជាអនត្តា បើដូច្នេះ ក៏បានដឹងថា ទោះបីខំប្រឹងព្យាយាមធ្វើឲ្យកើតសតិក៏មិនបាន បានជ្រាបថា សម្មាវាយាមៈ ការព្យាយាមត្រូវ ជាអង្គមគ្គ ១ ក្នុងមគ្គមានអង្គ ៨ , សេចក្តីព្យាយាមត្រូវមានលក្ខណៈ យ៉ាងណា ?

ធ- សម្មាវាយាមៈ ឬ សេចក្តីព្យាយាមត្រូវ បានដល់ វិរិយចេតសិក ។ក្នុងវិសុទ្ធិមគ្គ “ ខន្ធនិទ្ទេស ” សម្តែងលក្ខណៈវិរិយចេតសិកថា ភាពជាអ្នកឧស្សាហ៍ ឈ្មោះថា វិរិយៈ ។ គុណរបស់វិរិយៈ មានការឧស្សាហ៍ជាលក្ខណៈ មានការឧបត្ថម្ភសម្បយុត្តធម៌ដែលកើតរួមជារស “កិច្ច” មានការមិនរួញរាជាអាការប្រាកដ មានការតក់ស្លុតជាបទដ្ឋាន ។ ព្រោះព្រះបាលីថា អ្នកតក់ស្លុត រមែងតាំងសេចក្តីព្យាយាមដោយល្អ , ម្យ៉ាងទៀត មានវត្ថុជាហេតុ ក្នុងការផ្តើមសេចក្តីព្យាយាម ជាបទដ្ឋាន

ដែលបុគ្គលប្រារព្ធត្រឹមត្រូវហើយ គប្បីឃើញថា ជាឫសគល់នៃសព្វ-សម្បត្តិ ។

វិរិយៈ ជានាមធម៌មួយប្រភេទ ដែលយើងប្រកាន់ថា ជាតួខ្លួនពិតឬទេ ៗ , វិរិយៈ មានច្រើនប្រភេទ មានវិរិយៈដែលជាអកុសល និងវិរិយៈដែលជាកុសល ។ វិរិយៈដែលប្រព្រឹត្តទៅក្នុងទាន ក្នុងសីល ក្នុងការចម្រើនសមថៈ និងវិរិយៈដែលជាសម្មាវាយាមៈ ដែលជាអង្គមគ្គ ៨ ។

សម្មាវាយាមៈ ដែលជាអង្គមគ្គនោះ កើតរួមជាមួយនឹងសម្មាទិដ្ឋិ និង សម្មាសតិ កើតរួមជាមួយចិត្តដែលរលឹកដឹងលក្ខណៈរបស់រូបធម៌ នាមធម៌ ។ ការចម្រើនបញ្ញាឲ្យដឹងច្បាស់សភាវធម៌តាមសេចក្តីពិត នឹងត្រូវចម្រើនសតិបានរឿយ ៗ សម្មាវាយាមៈ ធ្វើឲ្យមានការព្យាយាមរលឹកដឹងលក្ខណៈរបស់រូបធម៌ នាមធម៌ ដែលប្រាកដ ។

ស- ដែលពោលថា បើសម្មាទិដ្ឋិដឹងលក្ខណៈរបស់រូបធម៌ នាមធម៌ ក៏មានសម្មាវាយាមៈកើតរួមជាមួយផង តែបើសតិកើតឡើងតិចតួច ៗ នឹងមិនគួរប្រឹងប្រែងព្យាយាមឲ្យកើតសតិច្រើន ៗ ទេឬ ។

ឆ- ការព្យាយាមឲ្យកើតសតិនោះ ព្រោះមានការយល់ខុសថា មានតួខ្លួន ប្រសិនបើគិតនឹងបង្គាប់បញ្ជាឲ្យសតិកើត និង ព្យាយាមចាប់អា-រម្មណ៍បច្ចុប្បន្ន ។ ជាការពិតដែលថា គួរចម្រើនសម្មាសតិ តែក៏មិនមែនថា នឹងបង្គាប់បញ្ជាសតិឲ្យកើតបាន មានន័យថា នឹងត្រូវមានការយល់ឲ្យបានត្រឹមត្រូវក្នុងលក្ខណៈរបស់នាមរូប និង ការបដិបត្តិ មិនគួរវង្វេងថា ការឃើញត្រូវ ជាអង្គដំបូងរបស់មគ្គអង្គ ៨ កាលបើចិត្តដឹងលក្ខណៈរបស់នាមរូប មានសម្មាទិដ្ឋិកើតជាមួយ ក៏មានសម្មាវាយាមៈកើតរួមផង , សម្មាវាយាមៈ ក្នុងមគ្គអង្គ ៨ ជាសេចក្តីព្យាយាមក្នុងផ្លូវកណ្តាល ជាមជ្ឈិមាបដិបទា ។

ស- ដំណើរការក្នុងមជ្ឈិមាបដិបទានោះ បើសេចក្តីព្យាយាមខ្លាំងពេក ក៏ជាការឃើញខុសថា មានតួខ្លួនទៀត បើមិនព្យាយាមសោះនោះក៏ជាការមិនអើពើ មិនដឹងថា នឹងប្រព្រឹត្តក្នុងផ្លូវកណ្តាល ដូចម្តេច ។

ឆ- បើគិតរឿងព្យាយាមខ្លាំងពេក ឬក៏តិចពេក ក៏នៅតែជាតួខ្លួនកុំច្រឡំសម្មាវាយាមៈដែលជាអង្គមគ្គ ជាមួយពាក្យថា ការប្រឹងប្រែងព្យាយាម ដែលយើងធ្លាប់ប្រើនោះ សម្មាវាយាមៈ ដែលជាមគ្គអង្គ ៨ កើតបានក្នុងខណៈមានសតិរលឹកដឹងសភាវធម៌ដែលកើតប្រាកដ ព្រោះ

ហេតុ-បច្ច័យ មិនមែនព្រោះការចូលចិត្តរបស់យើង មិនចាំបាច់គិតដល់រឿងព្យាយាមទេ ព្រោះខណៈណាដែលមានសម្មាសតិ ក៏មានសម្មាវាយាមៈដែរ ។ សម្មាវាយាមៈ កើតក្នុងខណៈដែលរលឹកដឹងលក្ខណៈរបស់សភាវធម៌ ដូចជា ការឃើញ ការឮ ការនឹកគិត និង រូប សំឡេង ជាដើម ដែលប្រាកដក្នុងខណៈនោះ ។

ស- ខ្ញុំយល់ថា ការព្យាយាមក្នុងការចម្រើនវិបស្សនាផ្សេងគ្នាជាមួយនឹងការចម្រើនសមថៈ , ពេលមានអកុសលចិត្តកើតឡើង ក៏ព្យាយាមឲ្យកុសលចិត្តកើត អ្នកដែលចម្រើនសមថភាវនា និង អ្នកដែលចម្រើនវិបស្សនា នឹងព្យាយាមឲ្យកើតកុសលចិត្តតាមវិធីផ្សេងគ្នា មិនមែនឬ ?

ឆ- អ្នកដែលចម្រើនសមថៈឲ្យចិត្តប្រត់ចំពោះអារម្មណ៍ដែលជាកម្មដ្ឋានដើម្បីរំងាប់អកុសលចិត្តជាខណៈ ជាវិរិយៈរបស់ការចម្រើនសមថៈដែលផ្សេងគ្នាជាមួយនឹងសម្មាវាយាមៈក្នុងមគ្គមានអង្គ ៨ , អ្នកដែលចម្រើនវិបស្សនាដឹងថា អកុសលចិត្តជានាមធម៌មួយប្រភេទ ដែលកើតឡើងព្រោះហេតុបច្ច័យ ទើបធ្វើឲ្យស្រាលស្ដើងនូវការប្រកាន់អកុសលចិត្តថា ជាតួខ្លួនបាន ខណៈដែលរលឹកដឹងនោះ ក៏មានសម្មាវាយាមៈ



កើតរួមផង ។

ចំណុចសំខាន់ នឹងត្រូវដឹងថា ចម្រើនសមថភាវនា ឬ វិបស្សនាភាវនា , អ្នកដែលពោលថា ចម្រើនវិបស្សនាភាវនា តែមិនរលឹកដឹងនូវលក្ខណៈរបស់អកុសលចិត្ត ក៏មិនបានចម្រើនមគ្គមានអង្គ ៨ ។ មនុស្សដោយច្រើនភ័យខ្លាចកិលេសដែលគ្រោតគ្រាត តែមិនឃើញទោសរបស់កិលេសដ៏ល្អិត ដែលសន្សំនៅក្នុងចិត្ត កិលេសដ៏ល្អិតនោះ មានទោសភ័យ ព្រោះជាបច្ច័យឲ្យកើតអកុសលចិត្ត និង អកុសលកម្មជាបច្ច័យឲ្យកើតហើយកើតទៀត ការចម្រើនវិបស្សនា ជាផ្លូវតែមួយដែលនឹងរំលត់កិលេសដ៏ល្អិតឲ្យអស់បាន ។

ស- ដែលពោលថា ខណៈដែលចិត្តរលឹកដឹងលក្ខណៈរបស់នាមធម៌ រូបធម៌នោះ មានសម្មាទិដ្ឋិ និង សម្មាវាយាមៈផង ក៏ពិតហើយ ប៉ុន្តែជាដំបូងនោះ នឹងមានសម្មាទិដ្ឋិបាន យ៉ាងណា ។

ឆ- កាលបើយល់អំពីការបដិបត្តិបានត្រឹមត្រូវហើយ ក៏ជាបច្ច័យឲ្យសតិចម្រើនឡើង និង ការឃើញត្រូវក្នុងសភាវធម៌ច្រើនឡើង ៗ ឃើញអវិជ្ជារបស់ខ្លួនឯងច្បាស់ឡើង ៗ ហើយក៏ឃើញគុណរបស់សតិ នឹង

បានយល់ថា មិនមានផ្លូវដទៃកម្ចាត់អវិជ្ជាក្រៅពីនេះឡើយ ការដឹងយ៉ាងនេះ គឺជាបច្ច័យឲ្យសម្មាវាយាមៈចម្រើនឡើងផងដែរ ។

អ្នកដែលមិនដឹងតាមសេចក្តីពិត គិតថា ដឹងលក្ខណៈនៃការឃើញ ការបានឮ និង រូប សំឡេងជាដើម ២-៣ ខណៈ ក៏ល្មមហើយ គេពោលថា គេដឹងនាមធម៌ និងរូបធម៌ ហើយគេអាចនឹងគិតថា គេដឹងលក្ខណៈរបស់នាមធម៌ និងរូបធម៌ តែគេនៅមិនទាន់ដឹងច្បាស់ក្នុងលក្ខណៈរបស់សភាវធម៌ គេមិនដឹងលក្ខណៈដែលផ្សេងគ្នានៃការបានឮ ជាមួយនឹងសំឡេង គេកាន់យកសំឡេងថា ឮ និងកាន់យកការឮថា សំឡេង ព្រោះគេមិនដឹងថា ខណៈនោះ អ្វីជាលក្ខណៈរបស់សំឡេង និង អ្វីជាលក្ខណៈនៃការឮ ។

ស- ខ្ញុំគិតថា ខ្ញុំដឹងលក្ខណៈដែលមិនទៀងរបស់ការឃើញ ដឹងថាការឃើញរលត់ទៅ ព្រោះនាមធម៌ដទៃប្រាកដ ដូចជា ខណៈដែលបានឮក៏បញ្ជាក់បានថា ការឃើញបានរលត់ទៅហើយ ។

ឆ- លោកបានដឹងសភាពមិនទៀង ដោយត្រឹមតែការគិតប៉ុណ្ណោះ មិនមែនដោយការប្រចក្សច្បាស់ចំពោះសភាវធម៌នោះទេ ពេលដែលគិតក្នុងរឿងឃើញនោះ មិនដឹងទេឬ ថា ចិត្តកើតរលត់មិនអាចរាប់បានប្រព្រឹត្តទៅជាវិថីចិត្ត ( ចិត្តដែលដឹងអារម្មណ៍តាមទ្វារ ) ផ្សេង ៗ គ្នា ។ បើមិនបានចម្រើនសតិរហូតដល់ញាណខ្ពស់ ៗ ទេ ក៏មិនអាចឃើញសភាពមិនទៀងរបស់ចិត្តបាន ។



ស- ជាការពិតដែលពោលថា ការដឹងច្បាស់ក្នុងភាពមិនទៀងនោះជាប្រការសំខាន់ ដរាបណានៅមិនទាន់ប្រចក្សច្បាស់សភាពមិនទៀង ក៏ប្រកាន់សភាវធម៌ថា ជាតួខ្លួន ធ្វើដូចម្តេចនឹងដឹងទាន់ចំពោះសភាពមិនទៀងរបស់ចិត្តបាន ។

ឆ- តួខ្លួន ដែលព្យាយាមដើម្បីឃើញសភាវធម៌តាមសេចក្តីពិតមិនបាន , បញ្ញាប៉ុណ្ណោះ ដែលអាចដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ក្នុងខណៈនោះបាន ។

ស- កាលផ្តើមចម្រើនសតិ សតិនឹងដឹងអ្វីបានខ្លះ

ឆ- សតិរលឹកដឹងលក្ខណៈរបស់សភាវធម៌ ដែលប្រាកដតាមទ្វារណាមួយក៏បាន តែនៅមិនទាន់មានការដឹងច្បាស់ក្នុងលក្ខណៈរបស់នាមធម៌ រូបធម៌ ។ បុគ្គលខ្លះប្រាប់ថា គេជឿថា អ្នកណាៗ ក៏ដឹងថា ការឮ

មិនមែនសំឡេង គេមានចម្ងល់ក្នុងចិត្តថា ដូចម្ដេចទើបមានការសង្ស័យអ្នកដែលពោលដូច្នេះ មិនទាន់បានដឹងសេចក្ដីផ្សេងគ្នារវាងការដឹងបែបបរិយត្តិ នឹងការដឹងច្បាស់លក្ខណៈរបស់សភាវធម៌ កាលបើអប់រំបញ្ញាឲ្យចម្រើនឡើងដោយការចម្រើនវិបស្សនា ទើបដឹងច្បាស់ក្នុងសភាវធម៌ដែលកំពុងប្រាកដក្នុងខណៈនេះបាន ។

ស- សភាវធម៌កើតព្រមគ្នាច្រើនយ៉ាង តើគួររលឹកដឹងសភាវធម៌ណាមុន ។

ឆ- ជាការពិត សភាវធម៌កើតព្រមគ្នាច្រើនយ៉ាង ដូចជា រូបរាង-កាយប្រកបដោយរូបច្រើនប្រភេទ កើតរលត់បន្តគ្នា ដី ទឹក ភ្លើង ខ្យល់កើតព្រមគ្នា នឹងរលត់ព្រមគ្នា តែចិត្តដឹងលក្ខណៈរបស់សភាវធម៌បានតែមួយ ព្រោះចិត្តមួយដួង ក៏ដឹងអារម្មណ៍តែមួយ ។ បើសម្មាសតិកើតរួមជាមួយចិត្ត ក៏រមែងរលឹកដឹងសភាវធម៌បានតែមួយ ពេលប្រាប់ថាលក្ខណៈរឹងប្រាកដ ក៏មិនមែនមានតែរូបរឹងមួយកើតឡើងក្នុងខណៈនោះដោយមិនមានរូបដទៃ ៗ កើតទេ , ពេលដែលពោលថា លក្ខណៈរឹងប្រាកដនោះ ក៏មានន័យថា ខណៈនោះ ចិត្តដឹងសភាវៈដែលរឹង បើសតិ



កើតរួមជាមួយចិត្តណា សតិក៏រលឹកដឹងអារម្មណ៍តែមួយជាមួយចិត្តនោះ ខណៈនោះសតិ ក៏រលឹកដឹងថា សភាពរឹងនោះ ជាលក្ខណៈរបស់រូបម្យ៉ាង មិនមែនជាតួខ្លួន ការដែលសតិរលឹកដឹងអារម្មណ៍ណានោះ បង្គាប់បញ្ជាមិនបាន មិនមានច្បាប់កំណត់ថា ឲ្យសតិរលឹកសភាវធម៌ ណាមុន ណាក្រោយ ស្រេចតែសតិដែលរលឹកដឹងនាមធម៌ណា ឬ រូបធម៌ណា ។

ការដឹងច្បាស់ក្នុងលក្ខណៈរបស់សភាវធម៌ ដោយការចម្រើនសតិ មិនមែនជាការដឹងបែបបរិយត្តិទេ ក្នុងព្រះសូត្រមានការសម្គាល់ថា ព្រះ-មានព្រះភាគត្រាស់រឿយ ៗ ពីការដឹងច្បាស់ក្នុងលក្ខណៈរបស់នាមធម៌ រូបធម៌ តាមទ្វារទាំង ៦ ដូចជា ៖

ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ សប្បាយសូត្រទី ១ ព្រះមាន-ព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយថា “ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងបដិបទាដែលជាគ្រឿងឧបការៈដល់និព្វាន ដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្ដាប់ ។ល។ ម្នាលភិក្ខុទាំងឡាយ បដិបទាដែលជាគ្រឿងឧបការៈដល់ព្រះនិព្វាន តើដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ រមែងឃើញថា ចក្ខុមិនទៀង រូបទាំងឡាយមិនទៀង ចក្ខុវិញ្ញាណមិនទៀង

ចក្ខុសម្ផស្សមិនទៀង សូម្បីសុខវេទនា ទុក្ខវេទនា ឬ អទុក្ខមសុខ-វេទនាដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏មិនទៀង ។ល។ .... ម្នាលភិក្ខុទាំងឡាយ នេះឯងជាបដិបទា ដែលជាគ្រឿងឧបការៈដល់ព្រះនិព្វាន ” ។

ការគិតពិចារណាថា សភាវធម៌ទាំងឡាយមិនទៀងនោះ នឹងធ្វើឲ្យសម្រេចព្រះនិព្វានបានឬ ? ការធ្វើឲ្យស្រោលស្តើងនូវការប្រកាន់ថាជា តួខ្លួនឲ្យអស់ទៅត្រឹមតែការនឹកគិតនោះ មិនបាន បញ្ញាដែលបានដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ដែលកំពុងប្រាកដប៉ុណ្ណោះ ទើបដឹងច្បាស់ក្នុងសភាវធម៌តាមសេចក្តីពិត កាលដឹងច្បាស់សភាវធម៌តាមសេចក្តីពិត ហើយក៏លះបង់ការឃើញខុសថា ជាតួខ្លួនពិត ៗ ។ អ្នកដែលយល់ខុសថា ដឹងសភាវធម៌ហើយ រមែងមិនយល់អត្ថន័យរបស់ព្រះសូត្រនេះ ហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ហើយ ត្រាស់ទៀតថា ចក្ខុ ចក្ខុវិញ្ញាណ រូបារម្មណ៍មិនទៀង ? ដើម្បីទ្រង់ទូន្មានដល់សាវកឲ្យចម្រើនសតិដើម្បីថ្ងៃណាមួយ នឹងបានដឹងសភាវធម៌តាមសេចក្តីពិត ។

ស- ខ្ញុំដឹងថា លំបាកនឹងដឹងលក្ខណៈដែលផ្សេងគ្នារវាងការឮ និង



សំឡេង បើមិនមានការព្យាយាមទេ តើនឹងដឹងបានយ៉ាងណា ក្នុងការផ្តើមដំបូង ៗ មិនត្រូវដឹងថា ការឮ និង សំឡេង ផ្សេងគ្នា មិនល្អទេឬ នឹងដឹងលក្ខណៈដែលផ្សេងគ្នារបស់រូប ដែលប្រាកដតាមផ្លូវកាយមិនល្អទេឬ ។

ឆ- នឹងត្រូវដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ ទាំងពួងដែលប្រាកដតាមទ្វារផ្សេង ៗ តែមិនគួរបោះចំពោះដល់ការរលឹកដឹងនាមណា រូបណាទាំងអស់ ការបោះចំពោះ មិនមែនជាសម្មាមគ្គ , នឹងត្រូវដឹងលក្ខណៈរបស់ការឮ និង សំឡេងផង បើដឹងត្រឹមការឮតែម្យ៉ាង ក៏ដូចគ្នានឹងថា លោកនេះ មិនមានសំឡេងឡើយ បើដឹងត្រឹមតែសំឡេង ក៏ដូចគ្នាថា មិនមាននាមធម៌ដែលដឹងសំឡេង , ទោះយ៉ាងណា ក៏មិនអាចដឹងច្បាស់ក្នុងលក្ខណៈរបស់សភាវធម៌ឲ្យបានរហ័ស ៗ ដែរ សូម្បីវិបស្សនាញាណដំបូង គឺ នាមរូបបរិច្ឆេទញាណ ( ញាណដឹងច្បាស់ក្នុងលក្ខណៈដែលផ្សេងគ្នារបស់នាមធម៌ រូបធម៌ ដោយសភាពមិនមែនជាតួខ្លួន ) ក៏នឹងកើតមិនបាន បើមិនបានចម្រើន ( ហេតុ ) គឺ សតិដែលសមគួរ ( ដល់ផល គឺ ញាណនោះ ) ឯង ។

ចំណែកលោក លោកគិតថា ចម្រើនសតិបានមាំមួនហើយឬ ដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ផ្សេង ៗ ដែលប្រាកដតាមទ្វារផ្សេង ៗ ហើយឬ ឈប់ប្រទឡំថា អារម្មណ៍ណា ប្រាកដតាមទ្វារណាហើយឬ ?

ស- មិនទាន់បានដូច្នោះទេ

ធ- តើមានការដឹងច្បាស់ក្នុងសភាវធម៌បានយ៉ាងណា បើមិនទាន់ដឹងលក្ខណៈរបស់សភាវធម៌ ដែលប្រាកដតាមទ្វារផ្សេង ៗ ។

ការពិចារណាដល់ហេតុផលទាំងនេះ នឹងធ្វើឲ្យដឹងខ្លួនថា ខ្លួនមានការដឹងតិចតួចណាស់ យ៉ាងណា អ្នកដែលមានការយល់ខុសថា បានដឹងសភាវធម៌តាមសេចក្ដីពិតហើយ ក៏មិនអាចចម្រើនបញ្ញាបាន តែបើដឹងខ្លួនថា ខ្លួននៅមានការដឹងបានតិចតួច គង់នឹងអប់រំបញ្ញាឲ្យចម្រើនបាន ។

កាលបានអប់រំបញ្ញា ក៏ផ្ដើមឃើញសេចក្ដីផ្សេងគ្នារវាងការដឹងបែបបរិយត្តិ នឹងការរលឹកដឹងលក្ខណៈរបស់សភាវធម៌ នឹងដឹងថា ការមានសតិត្រឹមតែជាខណៈ ៗ នោះ ក៏នៅមិនទាន់ល្មមគ្រប់គ្រាន់ គឺ ត្រូវចម្រើនសតិក្នុងការរលឹកដឹងលក្ខណៈរបស់នាមធម៌ រូបធម៌រឿយ ៗ និងឲ្យកាន់តែស្ទាត់ជាមួយនឹងលក្ខណៈរបស់សភាវធម៌ទាំងឡាយ ក៏នឹងបានដឹង



ច្បាស់លក្ខណៈរបស់នាមធម៌ រូបធម៌ កាន់តែក្រៃលែងឡើង បានដឹងថាការចម្រើនសតិប្បដ្ឋានមានប្រយោជន៍យ៉ាងណា ។ ការចម្រើនមគ្គមានអង្គ ៨ ជាផ្លូវតែមួយគត់ ដែលដឹងសភាវធម៌ទាំងឡាយតាមសេចក្ដីពិត ។

ស- សតិកើតឡើងញយ ៗ ប៉ុន្តែធ្វើយ៉ាងណា ទើបឲ្យសម្មាវាយាមៈចម្រើនឡើង នឹងបានទៅជាអ្នកមិនមានការធ្វេសប្រហែស ។

ធ- ព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងថា គួររួសរាន់ចម្រើនសតិ-ប្បដ្ឋាន ព្រះអង្គទ្រង់ប្រទានឱវាទដល់សាវ័កឲ្យចម្រើនសតិ មិនថានៅទីកន្លែងណា ពេលណា ព្រះអង្គទ្រង់ត្រាស់សម្ដែងសេចក្ដីទុក្ខរបស់អតីត-ជាតិ បច្ចុប្បន្នជាតិ អនាគតជាតិ បើបុគ្គលនោះមិនទាន់បានធ្វើឲ្យដល់ទីបំផុតនៃជាតិទេ ។

ក្នុងខុទ្ទកនិកាយ ទុកនិបាត វគ្គទី ៥ វជ្ជិតត្ថេរគាថា មានសេចក្ដីថាភិក្ខុវជ្ជិតសម្រេចព្រះអរហត្ត ហើយពោលថា ៖

កាលយើងនៅជាបុថុជ្ជនល្ងង់ខ្លៅ មិនឃើញអរិយសច្ច
បានត្រាច់រង្គាត់វិលវល់នៅក្នុងគតិទាំងឡាយអស់កាល
ដ៏យូរ ពេលនេះយើងជាអ្នកមិនប្រមាទ កម្ចាត់នូវ

សង្ស័រាបានហើយ គតិទាំងពួង ក៏យើងកាត់ផ្តាច់
ហើយ ពេលនេះភពថ្មីមិនមានទៀតឡើយ ។

យើងមិនដឹងថា យើងនឹងនៅក្នុងលោកនេះយូរត្រឹមណាមកហើយទេ និង មិនដឹងថា ជាតិមុខនោះ នឹងចម្រើនវិបស្សនាបានទៀតឬទេ ។ កាលបើសិក្សាព្រះធម៌ក្នុងរឿងកើត ចាស់ ឈឺ ស្លាប់ និង ភ័យរបស់ការកើត ក៏មិនមានសេចក្តីប្រមាទក្នុងការចម្រើនសតិ ក្នុងកាលដែលនឹងអាចធ្វើបាន កាលដឹងថា គួរប្រញាប់ប្រញាល់ចម្រើនសតិ សម្មាវាយាមៈ ក៏នឹងចម្រើនឡើង មិនត្រូវគិតថា នឹងតាំងចិត្តព្យាយាម ។ សម្មាវាយាមៈជាអង្គមគ្គមួយ ក្នុងមគ្គមានអង្គ ៨ ធ្វើឲ្យសតិរលឹកដឹងលក្ខណៈរបស់សភាវធម៌រឿយ ៗ មិនពន្យាពេលឡើយ , សភាវធម៌ ដូចជា ការឃើញពណ៌ ការឮ ការនឹកគិតជាដើម ដែលកើតរាប់មិនអស់ក្នុងមួយថ្ងៃៗ តែបើសតិមិនរលឹកដឹងក្នុងពេលនេះហើយ តើពេលណា ទើបឃើញច្បាស់សភាវធម៌ទាំងឡាយតាមសេចក្តីពិតបាន ។

ស- លោកពោលថា ការគិតដល់ភ័យរបស់ការកើតឡើង នឹងមិនធ្វើឲ្យមានការលះបង់ការចម្រើនសតិទេ ខ្ញុំនៅសង្ស័យថា សេចក្តីភ័យខ្លាចនរក នឹងមានប្រយោជន៍ខ្វះទេ ?



ឆ- ព្រះធម៌ ដែលព្រះមានព្រះភាគសម្តែងហើយ សុទ្ធតែមានប្រយោជន៍ទាំងអស់ ដូច្នោះយើងត្រូវសិក្សាព្រះធម៌ ព្រោះហេតុការណ៍ផ្សេង ៗ ក្នុងជីវិតរបស់យើង យើងនឹងបានឃើញថា ព្រះធម៌ដែលព្រះ-អង្គទ្រង់សម្តែងមកយ៉ាងសំបូរណ៍នោះ ធ្វើឲ្យអាចហ៊ាន រីករាយ ក្នុងការចម្រើនសតិ យើងកម្ចាត់បង់ការវង្វេងភ្លេចសតិរឿយ ៗ ។ តែបើសិក្សាព្រះធម៌អំពីការកើតក្នុងនរក ក៏ធ្វើឲ្យសតិកើតឡើង រលឹកបានទៀត ។ យើងមិនគួរខ្វាយខ្វល់ក្នុងរឿងនរក សេចក្តីកង្វល់ជាអកុសល តែយើងត្រូវដឹងថា ការចម្រើនវិបស្សនា ទើបដឹងច្បាស់នូវអរិយសច្ចធម៌ ដែលជាហេតុធ្វើឲ្យផុតចាកភ័យនៃការទៅកើតក្នុងអបាយភូមិបាន ។

ការដឹងតាមសេចក្តីពិតថា បានសន្សំកិលេសដ៏យ៉ាងច្រើនសន្ធឹកសន្ធាប់ពីត្រឹមណាមក និង នៅសន្សំតទៅទៀត ក៏ធ្វើឲ្យមានការរួសរាន់ក្នុងការចម្រើនមគ្គមានអង្គ ៨ ។

# សម្មាសតិ

ស- បើមិនមានសតិ ក៏ចម្រើនបញ្ញាដើម្បីដឹងសភាវធម៌តាមការពិតមិនបាន មានអ្វីដែលយើងគួរធ្វើខ្លះទេ ដើម្បីឲ្យកើតសតិជាមុន ហើយជាខាងក្រោយ បញ្ញាដែលដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ ក៏បានកើតឡើង ។

ឆ- បុគ្គលដោយច្រើនគិតថា សម្មាសតិក្នុងមគ្គមានអង្គ ៨ ជាអ្វីដទៃ ដែលមិនមែនជាការរលឹកដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ ដែលកំពុងតែប្រាកដក្នុងខណៈនេះ ខណៈនេះលោកកំពុងអង្គុយ មានរឹងប្រាកដទេ ដឹងបានទេ ។

ស- ដឹងបាន

ឆ- ខណៈរលឹកដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ដែលកំពុងប្រាកដតាមទ្វារណាមួយនោះ ក៏គឺសតិ , បុគ្គលដោយច្រើនគិតថា នឹងត្រូវធ្វើអ្វីឲ្យពិសេសដើម្បីឲ្យកើតសតិ និង គិតថា កាលតាំងចិត្តឲ្យកើតសតិហើយ ក៏នឹងដឹងលក្ខណៈរបស់នាមធម៌ រូបធម៌បាន ។

សម្មាសតិ ( ការរលឹកត្រូវ ) ជាអង្គមួយក្នុងមគ្គអង្គ ៨ កាលបើមាន



សម្មាទិដ្ឋិ ការឃើញត្រូវក្នុងលក្ខណៈរបស់នាមធម៌ រូបធម៌ ដែលប្រាកដតាមទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ក៏ត្រូវមានសម្មាសតិដែរ , សម្មាសតិ ត្រូវកើតរួមជាមួយនឹងសម្មាទិដ្ឋិ ។

ស- តែក៏ត្រូវចម្រើនសតិផង យើងមិនត្រូវធ្វើអ្វីពិសេស និង វៀរចាកមិនធ្វើអ្វីតាមប្រក្រតី ដើម្បីឲ្យមានសតិច្រើន ៗ ឬ ? ។

ឆ- ការសិក្សាធម៌ ការពិចារណាធម៌ ការសិក្សាក្នុងរឿងបដិបត្តិដែលត្រឹមត្រូវ ការដឹងគុណដ៏ច្រើនអនេក ទាំងនេះជាបច្ច័យឲ្យកើតសតិ បើជ្រាបថា សតិជាអនត្តា កើតឡើងព្រោះហេតុបច្ច័យ និង ដឹងបានពីការបដិបត្តិដោយខ្លួនឯងថា តាំងចិត្តឲ្យកើតសតិមិនបាន , យើងនឹងលើកចេញនូវអ្វីដែលយើងគិតថា ត្រូវធ្វើអ្វីឲ្យពិសេសដើម្បីមានសតិច្រើនៗ។

ស- បាទ ពិតមែន , ពេលអង្គុយស្ងៀម ៗ នៅផ្ទះ ហើយព្យាយាមឲ្យកើតសតិ សតិក៏មិនកើត ។

ឆ- អ្នកដែលមានការយល់ត្រឹមត្រូវថា គោលបំណងនៃការចម្រើនវិបស្សនានោះ គឺ ដើម្បីដឹងខ្លួនឯង និង ជីវិតប្រចាំថ្ងៃ ទើបគេមិនធ្វើអ្វីដែលខុសប្រក្រតី ដែលនឹងឲ្យកើតសតិច្រើន ៗ គេមិនបង្ខំខ្លួនឯង និង

វង់ចាំឲ្យសតិកើតនោះទេ ការអង្គុយស្ងៀម ៗ មិនធ្វើអ្វីសោះនោះជាប្រក្រតី របស់លោកឬ ? ។

ស- មិនមែនទេ ធម្មតា ខ្ញុំអានសៀវភៅខ្លះ សរសេរខ្លះ ឈរ ដើរ ហើយក៏ធ្វើអ្វី ៗ ទៀត ។

ឆ- បើដូច្នេះ លោកប្រាថ្នានឹងដឹងរឿងជីវិតប្រចាំថ្ងៃរបស់លោក លោកគួរបង្ខំចិត្តធ្វើអ្វីដែលខុសប្រក្រតីមែនទេ ។

ស- មិនគួរទេ ខ្ញុំយល់ហើយថា បើធ្វើអ្វីដែលធ្លាប់ធ្វើជាប្រក្រតីតាមដែលបានសន្សំមក ក៏ដឹងច្បាស់ខ្លួនឯង តែសតិក៏មានមួយរំពេចតើ ដឹងសភាវធម៌បានដូចម្តេច ។

ឆ- ខណៈរបស់សតិតិចណាស់ កើតឡើងហើយ ក៏រលត់ទៅវិញព្រមជាមួយចិត្ត សតិមិនទៀង មិនមែនតួខ្លួន សតិកើតហើយក៏រលត់ តែក៏កើតទៀត កាលបើមានហេតុបច្ច័យ ដូច្នោះ ការដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ ទើបផ្តើមឡើងបន្តិចម្តង ៗ ។ បើលោកមិនដឹងថាសតិជានាមធម៌ ដែលកើតឡើងព្រោះហេតុបច្ច័យ បែរជាទៅព្យាយាមតាំងចិត្តធ្វើឲ្យកើតសតិ លោកក៏ប្រកាន់ថា សតិជាតួខ្លួន និង បញ្ញា ក៏



ចម្រើនមិនបាន ។

ស- ខ្ញុំសង្កេតឃើញថា ពេលធ្វើកុសល សតិកើតរឿយ ៗ , ការធ្វើកុសលជាបច្ច័យឲ្យកើតសតិ មែនទេ ?

ឆ- ការឃើញត្រូវ ជាបច្ច័យរបស់សម្មាសតិក្នុងមគ្គមានអង្គ ៨ , កុសលកម្មជាប្រយោជន៍ តែមិនគួរគិតថា សតិកើតមិនបាន កាលបើមានអកុសលចិត្ត ព្រះមានព្រះភាគត្រាស់ថា ត្រូវដឹងសភាវធម៌គ្រប់យ៉ាង ការចម្រើនសតិ មិនគួរកំណត់ពេលវេលា និង ទីកន្លែងឡើយ ។

ស- តែថា អ្នកដែលផ្តើមចម្រើនសតិ មិនចាំបាច់នៅក្នុងទីណាដោយចំពោះទេឬ ?

ឆ- ប្រការសំខាន់ ក៏គឺ ការយល់ឲ្យបានត្រឹមត្រូវ , ការចម្រើនវិបស្សនាបានធ្វើឲ្យដឹងច្បាស់ក្នុងលោកទាំង ៦ គឺ លោកភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត យើងត្រូវពិចារណាឲ្យដឹងសេចក្តីផ្សេងគ្នារបស់លោកទាំង ៦ ដើម្បីឲ្យដឹងសច្ចធម៌ក្នុងលោកទាំង ៦ គ្រប់ទីកន្លែង មិនថា នៅទីកន្លែងណា ដូច្នោះទើបត្រូវរលឹកដឹងនាមធម៌ រូបធម៌ ក្នុងលោកទាំង ៦ ។

ស- ដំបូងៗ ក៏មានសតិត្រឹមតែបន្តិចបន្តួច ក៏កើតការនឿយណាយ ព្រោះគិតថា នឹងមិនកើតផលអ្វីឡើយ បើដូច្នោះ នៅក្នុងទីដែលស្ងាត់ៗ ក្នុងសម្នាក់បដិបត្តិប្រហែលជាល្អជាង មើល៍ទៅ ។

ឆ- ពេលចាប់ផ្តើមចម្រើនវិបស្សនា ក៏ប្រាថ្នាចង់បានផលរហ័ស ៗ ពេក ចង់ឃើញសភាពនៃនាមធម៌ រូបធម៌ ចង់លះបង់កិលេសឲ្យអស់ដោយរហ័ស បើខិតខំព្យាយាមបង្គាប់បញ្ជាសតិយ៉ាងនេះ ក៏មិនមែនជាសម្មាមគ្គ បុគ្គលដែលបដិបត្តិខុស មិនបានចម្រើនសម្មាសតិ បញ្ញាក៏ចម្រើនមិនបាន ។

អ្នកដែលមិនបានចម្រើនសតិ រលឹកដឹងសភាវធម៌ក្នុងជីវិតប្រចាំថ្ងៃ មិនបានចម្រើនមគ្គមានអង្គ ៨ អ្នកខ្លះក៏ពោលថា ពេលចម្រើនវិបស្សនា គេបែកតួខ្លួនចេញពីជីវិតប្រក្រតីប្រចាំថ្ងៃ គេហៅជីវិតដែលវង្វេង ដែលមិនមានសតិថា ជាជីវិតប្រក្រតីប្រចាំថ្ងៃ និង ជីវិតដែលមានសតិថា ជីវិតដែលប្រកបដោយកម្មដ្ឋាន ។ ដែលគេបែកការចម្រើនសតិចេញ និង ប្រកាន់ថា ជាចំណែកផ្សេងពីជីវិតប្រចាំថ្ងៃ គប្បីពិចាណាឲ្យឃើញថា គេ មិនបានចម្រើនមគ្គអង្គ ៨ នោះទេ ។



អ្នកខ្លះក៏លំបាកនឹងយល់ថា ការចម្រើនមគ្គមានអង្គ ៨ នោះ គឺជាការយល់ដឹងចំពោះជីវិតប្រចាំថ្ងៃ មគ្គមានអង្គ ៨ ជាមជ្ឈិមាបដិបទា បើមានសេចក្តីឃើញត្រូវច្រើនឡើង ៗ ក៏នឹងដឹងច្បាស់ថា ផ្លូវកណ្តាលនោះគឺអ្វី , នឹងដឹងថា មិនមានតួខ្លួនជាអ្នកសាងបញ្ញាឲ្យកើតរហ័ស ៗ នោះដែរ ការបដិបត្តិមជ្ឈិមាបដិបទា មិនមែនបង្ខំនូវវត្ថុដែលមិនបានសន្សំមកឲ្យកើតនោះទេ ប្រសិនបើមិនបានសន្សំមក នឹងរស់នៅដោយឯកោនេះសម្តែងឲ្យឃើញថា ការរស់នៅឯកោមិនមែនជាជីវិតពិតរបស់យើង ដូច្នោះ ទើបមិនគួរបង្ខំរស់នៅយ៉ាងនោះ ព្រោះមានការយល់ថា បញ្ញានឹងអាចកើតឡើង ។

ស- ខ្ញុំនៅគិតថា មានច្រើនយ៉ាងដែលមិនជាទីសប្បាយនៃការចម្រើនសតិ ដែលនឹងគួរលះបង់ ដូចជា ការអានសៀវភៅរឿងស្នេហាដែលមិនមែនជាសៀវភៅធម៌ និង សៀវភៅដែលមិនមានប្រយោជន៍ដល់ការដោះស្រាយដល់សង្គម ក៏មិនមែនជាកុសល យើងមិនគួរអានសៀវភៅទាំងនោះ ដើម្បីឲ្យសតិកើតច្រើន ៗ នោះទេឬ ។

ឆ- ពេលអានសៀវភៅដែលមិនមែនជាកុសល ក៏ព្រោះថា មាន

ការសន្សំមក ទើបធ្វើឲ្យមានការអាន ការគិតថា នឹងអានដើម្បីឲ្យសតិកើតឡើងនោះក៏ខុស ការធ្វើយ៉ាងនោះ នឹងមិនដឹងច្បាស់ខ្លួនឯង និងនឹងវង្វេងគិតថា មិនមានអកុសលចិត្តទៀតផង ។ ខណៈសតិរលឹកដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ ដែលប្រាកដក្នុងខណៈអាននោះ ជាមជ្ឈិមាបដិបទា ជាផ្លូវដែលធ្វើឲ្យដឹងច្បាស់ដោយខ្លួនឯង អាចរលឹកដឹងថា ការឃើញ ជានាមធម៌មួយប្រភេទ ការដឹងអត្ថរបស់ពាក្យដែលអាននោះ ក៏ជានាមធម៌មួយប្រភេទ អាចមានការភ្លើតភ្លើនទៅក្នុងរឿងដែលបានអាន និង កើតសេចក្តីពេញចិត្ត ឬ ទាស់ចិត្ត សភាវធម៌នោះ ៗ ក៏ជានាមធម៌មួយប្រភេទ ។ ខណៈដែលអានសៀវភៅ មាននាមធម៌ និង រូបធម៌ច្រើនប្រភេទប្រាកដ បើសតិមិនកើតក្នុងខណៈនោះ ក៏មានការប្រកាន់ថា ជាតួខ្លួនអ្នកអានសៀវភៅ ។

បើយើងសន្សំមកក្នុងរឿងតន្ត្រី ឬ គំនូរ ក៏មិនត្រូវគេចវេស ។ ពេលលេងតន្ត្រី ឬ កំពុងគូរ ក៏មាននាមធម៌ រូបធម៌ ប្រាកដតាមទ្វារទាំង ៦ ហេតុអ្វី រលឹកដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ទាំងឡាយនោះមិនបាន កាលរលឹកដឹង ក៏ដឹងច្បាស់ថា មួយជីវិតរបស់យើងនោះ មិនមាន



អ្វីក្រៅអំពីនាមធម៌ និង រូបធម៌ មិនត្រូវទៅស្វែងរកនាមធម៌ រូបធម៌ក្នុងកន្លែងដែលឯកោនោះទេ , នាមធម៌ រូបធម៌ មានប្រាកដហើយ ។

ស- ប៉ុន្តែថា ប្រសិនបើយើងអានសៀវភៅដែលមិនមានប្រយោជន៍ ឬផឹកស្រា មិនជាការហាមឃាត់សតិទេឬ ? ខ្ញុំសង្ស័យថា ជាផ្លូវកណ្តាល ឬមិនមែន ដឹងថា អកុសលនឹងកើនឡើងច្រើន នឹងថយចុះ ។

ឆ- វេលាមានសតិ ជាកុសលចិត្ត ដែលជំនួសអកុសលចិត្ត អកុសលចិត្តរមែងកើត សតិក៏រលឹកដឹងលក្ខណៈរបស់អកុសលចិត្ត សតិ នឹងការពារអកុសលកម្មបថតាមទ្វារកាយ វាចា ចិត្ត ។ បើសតិកើតញឹកញាប់ បច្ច័យដែលឲ្យកើតអកុសលចិត្ត ក៏ថយចុះ យើងនឹងដឹងបានដោយខ្លួនឯងថា ជាការពិត ឬ មិនពិត ។ យើងនឹងដឹងថា ការចម្រើនសតិ សូម្បីមួយខណៈ ៗ ក៏មានប្រយោជន៍ដ៏ច្រើន និងមានផលដ៏ច្រើន ។

បុគ្គលដែលចម្រើនបញ្ញា រហូតដឹងច្បាស់ក្នុងលក្ខណៈរបស់នាមធម៌ រូបធម៌ តាមសេចក្តីពិតនោះ រមែងអាចនឹងចាក់ធ្លុះអរិយសច្ចធម៌ជាព្រះសោតាបន្នបាន សូម្បីក្នុងខណៈក្រោយពីការរលឹកដឹងលក្ខណៈរបស់អកុសលចិត្ត បញ្ញានោះ អាចប្រច័ក្សលក្ខណៈមិនទៀង ជាទុក្ខ

ជាអនត្តារបស់នាមធម៌ រូបធម៌បាន មិនថា សភាវធម៌ណា ៗ ដែលប្រាកដ ។ បញ្ញាចម្រើនឡើងក្នុងជីវិតប្រចាំថ្ងៃ និង ការដឹងច្បាស់អរិយសច្ចធម៌នោះ ក៏កើតឡើងបានក្នុងជីវិតប្រចាំថ្ងៃ ។

កាលបានដឹងដោយខ្លួនឯងថា ព្រះធម៌ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែង គឺ មជ្ឈិមាបដិបទា ជាផ្លូវតែមួយពិត ៗ ដែលនាំទៅកាន់ទីរំលត់កិលេសហើយ សេចក្តីជ្រះថ្លាក្នុងព្រះធម៌ក៏មាំទាំឡើង ។ យើងមិនគួរភ័យព្រួយអំពីការចម្រើនសតិក្នុងជីវិតប្រចាំថ្ងៃ ហើយយើងនឹងកាន់តែដឹងច្បាស់ដោយខ្លួនឯង និងក្នុងទីបំផុត ក៏អស់សេចក្តីសង្ស័យក្នុងវត្ថុដែលខ្លួនប្រកាន់ថា ជាតួខ្លួន ឃើញមានត្រឹមតែនាមធម៌ និង រូបធម៌ប៉ុណ្ណោះ ។

ស- សតិ ត្រូវអប់រំចម្រើនក្នុងជីវិតប្រចាំថ្ងៃ តែបើគិតដល់ថ្ងៃដែលកន្លងទៅ ដឹងថា សតិកើតបានតិចណាស់ ក៏មានការសោកស្តាយដល់ពេលវេលាដែលកន្លងទៅមិនបាន ខ្ញុំដឹងថា ការសោកស្តាយជាអកុសល តែមិនដឹងធ្វើយ៉ាងណា ហាមឃាត់ការសោកស្តាយបាន ។

ធ- អ្នកចង់មានសតិច្រើន ៗ តែគេមិនដឹងថា គេត្រូវការសតិ



ដើម្បីអ្វី ។ គោលបំណង មិនមែនការមានសតិដោយគ្មានការដឹងអ្វីនោះទេ គោលបំណង គឺ ការដឹងសភាវធម៌តាមសេចក្តីពិត ដឹងថា សភាពរបស់សង្ខារធម៌ មិនទៀង ជាទុក្ខ ជាអនត្តា ។ តើយើងដឹងសភាវធម៌តាមសេចក្តីពិត បានយ៉ាងណា ? ដឹងបាន ព្រោះការមានសតិរលឹកដឹងសភាវធម៌ដែលកំពុងប្រាកដក្នុងខណៈនេះ ។

បើសភាវធម៌ក្នុងខណៈនេះជាសេចក្តីសោកស្តាយ ក៏គួររលឹកដឹងថាលក្ខណៈនោះ ជានាមធម៌មួយប្រភេទ ក៏នឹងធ្វើឲ្យសេចក្តីសោកស្តាយថយចុះ ហើយសតិក៏កើតឡើងជំនួស លោកនឹងដឹងថា សភាវធម៌ទាំងឡាយកើតព្រោះហេតុបច្ច័យ តើប្រយោជន៍អ្វីគួរសោកស្តាយ ។ បើមិនរលឹកដឹងថា សេចក្តីសោកស្តាយជានាមធម៌មួយប្រភេទទេ ក៏នឹងជាតួខ្លួន ដែលសោកស្តាយ ។

ស- សតិត្រូវដឹងអារម្មណ៍ជានិច្ចឬ ? បានឮអ្នកខ្លះ ប្រាប់ថាពេលមានសតិច្រើន ៗ ហើយមិនដឹងអ្វី ក្រៅពីសេចក្តីស្ងៀមស្ងាត់ ។

ធ- សតិ ត្រូវដឹងអារម្មណ៍ សតិជាសោភណចេតសិកកើតរួមជាមួយសោភណចិត្ត ចិត្តគ្រប់ដួងត្រូវដឹងអារម្មណ៍ និងចេតសិកទាំងឡាយ

ណា ដែលកើតជាមួយចិត្តដួងណា ក៏ដឹងអារម្មណ៍តែមួយជាមួយចិត្តដួងនោះ ។ សតិក្នុងសមថភាវនា ក៏ដឹងអារម្មណ៍តែមួយ ជាមួយចិត្តដែលតាំងមាំក្នុងអារម្មណ៍សមថកម្មដ្ឋាន , សតិក្នុងការចម្រើនវិបស្សនា ក៏ដឹងអារម្មណ៍តែមួយជាមួយចិត្ត ដែលកើតរួមគ្នា គឺ ដឹងលក្ខណៈរបស់នាមធម៌ ឬ រូបធម៌ ។

បុគ្គលដោយច្រើន ប្រាថ្នាចង់បានសេចក្តីស្ងៀមស្ងាត់ ដែលគេត្រូវការសេចក្តីស្ងៀមស្ងាត់នោះដើម្បីអ្វី គេគិតថា ការធ្វើដូច្នោះជាការចម្រើនបញ្ញាឬ ? សភាពដ៏ល្អិតរបស់ចិត្ត គេមិនត្រូវការដឹងអ្វីទេ គេត្រឹមតែត្រូវការសេចក្តីស្ងប់ប៉ុណ្ណោះ វិបស្សនាភាវនា មិនមែនជាសមថភាវនា វិបស្សនា ជាញាណ , ញាណ ជាបញ្ញា , វិបស្សនា ជាបញ្ញាមួយប្រភេទ គឺ ជាបញ្ញាដែលដឹងសភាវធម៌ទាំងឡាយតាមសេចក្តីពិត ។

ស- ព្រះមានព្រះភាគ ត្រាស់ឲ្យចម្រើនសតិគ្រប់ខណៈ សូម្បីមុនពេលដេកលក់ ក៏គួរចម្រើនសតិ ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសកៈ មូលបរិយាយវគ្គ សតិប្បដ្ឋានសូត្រ ព្រះមានព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយថា “ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ភិក្ខុជាអ្នកធ្វើសម្បជញ្ញៈ



ក្នុងការឈានទៅមុខ និង ឈានត្រឡប់ ក្នុងការក្រឡេកមើលទៅមុខ និង ខាងទទឹង ក្នុងការបត់ចូលនូវអវយវៈ និង លាចេញ ក្នុងការស្ពៀកដណ្តប់សំពត់សង្ឃាដី បាត្រ និង ចីវរ ក្នុងការស៊ី ផឹក ទំពាលិទ្ធ ក្នុងការបន្ទោបង់ឧច្ចារៈ បស្សាវៈ ក្នុងវេលាដើរ អង្គុយ ដេកលក់ ភ្ញាក់ និយាយ ស្ងៀម ដូចពណ៌នាមកនេះ ភិក្ខុរមែងពិចារណាឃើញកាយក្នុងកាយ ” ។

ខ្ញុំមិនយល់ថា ពេលដេកលក់ មានសតិបានដូចម្តេច ពេលយល់សប្តិ ក៏ជាកុសលចិត្តបាន តែដោយច្រើនជាអកុសលចិត្ត ពេលដេកលក់យ៉ាងស៊ប់ មិនមានការយល់សប្តិ ក៏ជាភវង្គចិត្ត ( ចិត្តដែលកើតរលត់បន្តគ្នា តម្រង់ភពជាតិ ) ដែលមិនដឹងអារម្មណ៍ផ្លូវទ្វារទាំង ៦ ។

ឆ- បើអប់រំចម្រើនសតិរឿយ ៗ សតិក៏កើតមុនពេលដេកលក់បាន បើសតិមិនកើត ក៏អាចនឹងកើតលោភៈដែលពេញចិត្តក្នុងការដេកយ៉ាងសប្បាយ ឬអាចកង្វល់ក្នុងរឿងផ្សេង ៗ ដែលកើតឡើងក្នុងថ្ងៃនោះ ទោសៈក៏កើតឡើង ។ បើយើងមិនរលឹកដឹងលក្ខណៈរបស់លោភៈ ទោសៈ និងនាមធម៌រូបធម៌ដទៃ ៗ យើងដេកលក់ទៅដោយអកុសលចិត្ត

បើសតិកើតមុនពេលដេកលក់ ក៏ជាបច្ច័យឲ្យសតិកើតទាន់ពេលដែលភ្ញាក់ឡើងក៏បាន ។

យើងមិនដឹងថា ស្លាប់ពេលណា បើយើងចម្រើនសតិជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃ ក៏មានបច្ច័យឲ្យសតិកើតមុនពេលអស់ជីវិតបាន ចិត្តដែលកើតមុនខណៈចុតិ ជាបច្ច័យដល់បដិសន្ធិចិត្តក្នុងជាតិតទៅ យើងគួរចម្រើនសតិ សូម្បីក្នុងខណៈមុនពេលដេកលក់ ។

ស- ព្រះមានព្រះភាគត្រាស់ថា គួរចម្រើនសតិក្នុងខណៈនិយាយ និង នៅស្ងៀម ខ្ញុំរលឹកថា ពេលនិយាយជាមួយអ្នកណា ៗ មានការចម្រើនសតិលំបាកណាស់ ។

ធ- លោកគិតថា លោកចម្រើនសតិមិនបាន ព្រោះលោកនៅជឿថា ការចម្រើនសតិ នឹងត្រូវធ្វើអ្វីឲ្យពិសេស ពេលដើរ សតិកើតបានឬទេ ?

ស- កើតបាន ដូចជា មានលក្ខណៈរឹង ញ័រ ឬ តឹង ប្រាកដឲ្យដឹងបាន ។

ធ- ពេលនិយាយ មិនមានសភាវៈរឹង ឬ សភាវៈដែលកម្រើក



ញ័រឬ ?

ស- មាន

ធ- ពេលនិយាយមានឮ មានឃើញ ដែរឬទេ , ត្រូវឈប់និយាយជាមុនសិន ទើបដឹងថា មានសំឡេងឬ ។

ស- មិនមែនទេ កំពុងនិយាយ ក៏ដឹងបាន ។

ធ- ខណៈកំពុងនិយាយ រលឹកដឹងមិនបានឬ ថាសំឡេង ក៏ជារូបធម៌ម្យ៉ាង , ពេលនិយាយ មានសភាវធម៌ម្យ៉ាងកើតឡើងប្រាកដក្នុងខណៈផ្សេង ៗ គ្នា មិនមែនឈប់និយាយ ទើបរលឹកដឹងបាននោះទេ , ការនិយាយនោះកើតឡើងព្រោះអកុសលចិត្តខ្លះ កុសលចិត្តខ្លះ ហេតុអ្វីទើបរលឹកដឹងសភាពរបស់ចិត្តទាំងនោះមិនបាន ។ ពេលនិយាយរឿងអកុ-សល ពេលសើច និង ពេលសប្បាយចិត្ត យើងចេះតែគិតថា មិនអាចរលឹកដឹងសភាវធម៌ក្នុងខណៈនោះបាន តែសភាវធម៌ទាំងឡាយ ក៏គឺនាមធម៌ រូបធម៌នោះឯង សតិរលឹកដឹងមិនបានឬ ? ។

ពេលនៅកន្លែងធ្វើការងារ លោកទូរស័ព្ទញឹកញាប់ដែរទេ លោកមានសតិពេលដែលលើកទូរស័ព្ទ និយាយខ្លះទេ ។

ស- ពេលកណ្ដឹងទូរស័ព្ទរោទិ៍ ខ្ញុំក៏លើកទូរស័ព្ទ មិនដឹងជាមានអ្វីច្រើនយ៉ាងកើតឡើង ការចម្រើនសតិក្នុងកន្លែងធ្វើការងារ មានការលំបាកណាស់ ។

ឆ- មិនមានសភាវធម៌ប្រាកដតាមទ្វារទាំង ៦ ទេឬ លោករលឹកដឹងសភាវធម៌គ្រប់ពេលមិនបាន តែលោកនឹងផ្ដើមមានសតិបន្តិចម្ដង ៗ សូម្បីនៅក្នុងកន្លែងធ្វើការក៏ដោយ លោកអាចដឹងខ្លួនឯងក្នុងខណៈលើកទូរស័ព្ទ ឬពេលផ្ដើមនិយាយ ហើយក៏អាចរីករាយក្នុងរឿងនិយាយ ព្រោះមិនមានសតិ តែបើក្នុងពេលខ្លះលោកមានសតិ ក៏ជាបច្ច័យធ្វើឲ្យមានសតិតាំងមាំបាន ។

ស- អ្នកខ្លះគិតថា កាលសតិមិនទាន់មាំទាំ ក៏ត្រូវនៅតែម្នាក់ឯងដើម្បីចម្រើនសតិ តើត្រូវទេ ។

ឆ- ខណៈមានសតិរលឹកដឹងលក្ខណៈរបស់នាមធម៌ និង រូបធម៌នោះ ក៏ជាការនៅតែម្នាក់ឯងជាមួយនឹងសភាវធម៌នោះ ហើយខណៈនោះលក្ខណៈរបស់សភាវធម៌នោះប៉ុណ្ណោះ ដែលប្រាកដច្បាស់ការនៅតែម្នាក់ឯងក្នុងការបដិបត្តិធម៌ មិនមែនជារឿងទីកន្លែងទេ សូម្បីនៅជាមួយ



មនុស្សច្រើន ៗ ក៏រលឹកដឹងលក្ខណៈរបស់នាមធម៌ និង រូបធម៌បាន ។ យើងមិនត្រូវបញ្ឈប់កិច្ចការប្រចាំថ្ងៃ ដើម្បីចម្រើនសតិទេ ព្រោះសភាវ-ធម៌គ្រប់ប្រភេទដែលប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ជាសតិប្បដ្ឋានបានទាំងអស់ ។ ដោយហេតុនេះ សូម្បីនៅជាមួយមនុស្សច្រើន ៗ ក៏ជាការនៅតែម្នាក់ឯងជាមួយនាមធម៌ និង រូបធម៌ដែលប្រាកដក្នុងខណៈនោះ , ប្រសិនបើយើងទៅនៅក្នុងទីស្ងាត់ដើម្បីចម្រើនសតិ មិនអាចនៅតែម្នាក់ឯងជាមួយនាមធម៌ រូបធម៌ ក៏ថាបាន ។

ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ មិគជាលសូត្រទី ១ មានសេចក្ដីថា នគរសាវត្ថី ។ល។ គ្រានោះឯង ព្រះមិគជាលៈចូលទៅគាល់ព្រះ-មានព្រះភាគ ថ្វាយបង្គំហើយក៏អង្គុយក្នុងទីដ៏សមគួរ លុះអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលសួរព្រះមានព្រះភាគថា ៖

“ បពិត្រព្រះអង្គដ៏ចម្រើន ដែលព្រះអង្គត្រាស់ថា អ្នកមានប្រក្រតីនៅតែម្នាក់ឯង អ្នកមានប្រក្រតីនៅតែម្នាក់ឯង ដូច្នេះ ដោយហេតុត្រឹមណាព្រះអង្គ ភិក្ខុទើបឈ្មោះថា មានប្រក្រតីនៅតែម្នាក់ឯង និង ដោយហេតុត្រឹមណា ភិក្ខុឈ្មោះថា នៅដោយមានគ្នា ២ នាក់ ” ។

ព- “ ម្នាលមិគជាលៈ រូបដែលបានដឹងដោយចក្ខុ ដែលគួរ ប្រាថ្នា គួររីករាយ គួរពេញចិត្ត ឲ្យកើតសេចក្តីស្រទឡាញ់ កាន់តែរីករាយ ឲ្យកើតតម្រេក មានហើយ បើភិក្ខុត្រេកអរ ពោលសរសើរ ងប់ជ្រុប ក្នុងរូបនោះ , កាលបើអ្នកត្រេកអរ ពោលសរសើរ ងប់ជ្រុបក្នុងរូបនោះ រមែងកើតសេចក្តីភ្ញើតភ្ញើន កាលបើមានសេចក្តីភ្ញើតភ្ញើន ក៏មានការប្រកាន់មាំ កាលបើមានសេចក្តីប្រកាន់មាំ ក៏រមែងជាប់នៅ ម្នាលមិគ-ជាលៈ ភិក្ខុអ្នកប្រកបដោយសេចក្តីភ្ញើតភ្ញើន មានការជាប់នៅយ៉ាងនេះឯង តថាគតពោលថា អ្នកមានប្រក្រតីនៅដោយសំទឡាញ់ជាគម្រប់ពីរ.... ម្នាលមិគជាលៈ ភិក្ខុអ្នកមានប្រក្រតីនៅដោយអាការយ៉ាងនេះ ពេលសេព សេនាសនៈដែលស្ងាត់ សមគួរជាទីនៅដ៏ស្ងាត់ក៏ពិត តែក៏នៅឈ្មោះថា មានប្រក្រតីនៅដោយសំឡាញ់ជាគម្រប់ពីរ ។

សេចក្តីនោះ ព្រោះហេតុអ្វី ព្រោះអ្នកនោះនៅមានតណ្ហាជាសំឡាញ់គម្រប់ពីរ គេលះបង់តណ្ហាមិនទាន់បាន ដូច្នោះ ទើបហៅថា មានប្រក្រតីនៅដោយសំឡាញ់ជាគម្រប់ពីរ ។

ម្នាលមិគជាលៈ រូបដែលគប្បីដឹងច្បាស់ដោយចក្ខុ គួរប្រាថ្នា គួររីករាយ គួរពេញចិត្ត ឲ្យកើតសេចក្តីស្រឡាញ់ កាន់តែរីករាយ ឲ្យកើតតម្រេក មានហើយ បើភិក្ខុមិនត្រេកអរ .......... សេចក្តីភ្ញើតភ្ញើន រមែងរលត់ កាលបើមិនមានសេចក្តីភ្ញើតភ្ញើន ក៏មិនមានតម្រេក កាលបើមិនមានតម្រេក ក៏មិនមានការជាប់នៅ ម្នាលមិគជាលៈ ភិក្ខុអ្នកមិនប្រកបដោយសេចក្តីភ្ញើតភ្ញើន និង ការជាប់នៅ តថាគតពោលថា មានប្រក្រតីនៅតែម្នាក់ឯង ។ល។

........ ម្នាលមិគជាលៈ ភិក្ខុអ្នកមានប្រក្រតីនៅដោយអាការយ៉ាងនេះ សូម្បីនៅលាយឡំជាមួយនឹងភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា មហាអមាត្យរបស់ព្រះរាជា តិរ្ថិយ៍ សាវកតិរ្ថិយ៍ ក្នុងទីបំផុតនៃស្រុកក៏ពិត សូម្បីយ៉ាងនោះ ក៏មានឈ្មោះថា មានប្រក្រតី នៅតែម្នាក់ឯង

............. សេចក្តីនោះ ព្រោះហេតុអ្វី ព្រោះតណ្ហា ដែលជាសំឡាញ់ជាគម្រប់ពីរ អ្នកលះបង់បានហើយ ព្រោះហេតុនោះ ទើបហៅថា ជាអ្នកមានប្រក្រតីនៅតែម្នាក់ឯង ” ។

# សម្មាសមាធិ

ស- គោលបំណងក្នុងការចម្រើនមគ្គមានអង្គ ៨ មិនមែនដើម្បីសេចក្ដីស្ងប់ តែដើម្បីបញ្ញា , មគ្គមានអង្គ ៨ នោះ មិនមានសេចក្ដីស្ងប់ផងទេឬ ? បានជ្រាបថា សម្មាសមាធិ ( ការតំកល់ចិត្តត្រូវ ) ក៏ជាអង្គមគ្គ ១ ក្នុងមគ្គមានអង្គ ៨ ។

ឆ- សម្មាសមាធិ ជាចេតសិក ជាឯកគ្គតាចេតសិក ។ ឯកគ្គតា-ចេតសិក ឬ សមាធិនោះ កើតរួមជាមួយចិត្តគ្រប់ដួង កិច្ចរបស់ឯកគ្គតា-ចេតសិក គឺ តាំងមាំក្នុងអារម្មណ៍ ចិត្តគ្រប់ដួង ដឹងអារម្មណ៍បានតែមួយប៉ុណ្ណោះ ។

សម្មាសមាធិ ក្នុងសមថភាវនា ជាសភាវធម៌ ដែលតាំងមាំក្នុងអារម្មណ៍ ដែលជាសមថកម្មដ្ឋាន ដើម្បីឲ្យកើតសេចក្ដីស្ងប់ សម្មាសមាធិក្នុងមគ្គមានអង្គ ៨ កើតរួមជាមួយនឹងសម្មាទិដ្ឋិ និង សម្មាសតិ ដែលមានលក្ខណៈរបស់នាមធម៌ រូបធម៌ ដែលប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ជាអារម្មណ៍ ។

ស- លោកប្រាប់ថា កិច្ចរបស់សម្មាសមាធិក្នុងមគ្គមានអង្គ ៨ គឺ



តាំងមាំក្នុងលក្ខណៈរបស់នាមធម៌ និង រូបធម៌ ដែលជាអារម្មណ៍របស់សតិក្នុងខណៈនោះ ដឹងថា នឹងត្រូវកំណត់ដល់សភាវរបស់នាមធម៌ រូបធម៌ ដូចគ្នា តែបើដូច្នោះ ក៏ចម្រើនសតិក្នុងខណៈធ្វើកិច្ចការងារតាមប្រក្រតីប្រចាំថ្ងៃមិនបាន ។

ឆ- ការតាំងមាំក្នុងលក្ខណៈរបស់នាមធម៌ រូបធម៌ ដែលប្រាកដ មិនមែនជាការកំណត់ឲ្យយូរ ៗ ដូចក្នុងការចម្រើនសមថភាវនាទេ សម្មា-សមាធិក្នុងមគ្គមានអង្គ ៨ កើតរួមជាមួយចិត្តដែលដឹងលក្ខណៈរបស់នាមធម៌ ឬ រូបធម៌ ហើយក៏រលត់ទៅព្រមជាមួយចិត្តដួងនោះ ។ សម្មា-សមាធិ ក្នុងការចម្រើនវិបស្សនា ជាខណិកសមាធិ ( សមាធិជាខណៈ ៗ ) ការចម្រើនវិបស្សនា មិនមែនព្យាយាមសំឡឹងសភាវធម៌ ដែលប្រាកដយូរ ៗ ទេ គោលបំណងនៃការចម្រើនវិបស្សនា មិនមែនជាការជាប់ជំពាក់ តែដើម្បីការលះបង់ ដោយការចម្រើនបញ្ញា ។

សមាធិ ក្នុងការចម្រើនវិបស្សនា មិនមែនជាឧបសគ្គដល់កិច្ចការ-ងារក្នុងជីវិតប្រចាំថ្ងៃនោះទេ តួយ៉ាងដូចជា ក្នុងខណៈនិយាយជាមួយអ្នកដទៃ ក៏មាននាមធម៌ រូបធម៌ ប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ

អណ្តាត កាយ ចិត្ត ហេតុអ្វី រលឹកដឹងសភាវធម៌ទាំងនោះ មិនបាន ? , សតិមិនមែនធ្វើឲ្យយើងឈប់និយាយទេ បើលក្ខណៈរបស់នាមធម៌ណា ឬ រូបធម៌ណាប្រាកដ សតិក៏រលឹកដឹងបានក្នុងខណៈនោះ នឹងធ្វើឲ្យលក្ខណៈរបស់អារម្មណ៍នោះប្រាកដច្បាស់ឡើង ។

ស- ធ្វើដូចម្តេច ទើបនឹងតាំងមាំបានក្នុងនាមធម៌ រូបធម៌ដែលប្រាកដក្នុងខណៈនេះ បានច្រើន , មានសតិក្នុងជីវិតប្រចាំថ្ងៃ តែក៏នៅមិនមានការដឹងច្បាស់ក្នុងលក្ខណៈរបស់អារម្មណ៍ដែលប្រាកដ ខ្ញុំបានសង្កេតឃើញថា មានសតិ តែមិនដឹងលក្ខណៈរបស់អារម្មណ៍តាមសេចក្តីពិត ។

ឆ- ខណៈកំពុងចម្រើនមគ្គមានអង្គ ៨ នោះ ក៏មិនមែនថា នឹងមានការដឹងលក្ខណៈរបស់សភាវធម៌គ្រប់ពេលដែលមានសតិនោះទេ ព្រោះការដឹងមានច្រើនប្រភេទ ជាដំបូង ៗ ការដឹង នៅមិនទាន់ជាក់ច្បាស់ តែក៏នឹងចម្រើនឡើង កាលមានសតិកើតឡើងញឹកញាប់ និងផ្តើមរលឹកដល់លក្ខណៈផ្សេងគ្នារបស់សភាវធម៌ កាលបើសតិចម្រើនឡើង ការដឹងលក្ខណៈរបស់សភាវធម៌ ក៏ជាក់ច្បាស់ឡើង ។



ការចម្រើនវិបស្សនា មិនត្រូវធ្វើអ្វីឲ្យខុសប្រក្រតី ដើម្បីឲ្យចិត្តតាំងមាំក្នុងសភាវធម៌ដែលប្រាកដ ខណៈណាដែលមានសម្មាសតិក្នុងមគ្គមានអង្គ ៨ ខណៈនោះ ក៏មានសម្មាសមាធិក្នុងមគ្គមានអង្គ ៨ ដែរ ។

ស- អ្នកខ្លះប្រាប់ថា ត្រូវចម្រើនសមថភាវនាជាបាទជាមុនសិន ទើបចម្រើនវិបស្សនាភាវនាបាន គេគិតថា សមាធិដែលកើតពីការចម្រើនសមថភាវនានោះ ជាសម្មាសមាធិក្នុងមគ្គមានអង្គ ៨ ។

ឆ- ចំណុចសំខាន់របស់ការចម្រើនសមថភាវនា ដើម្បីឲ្យចិត្តស្ងប់ចាកលោភៈ ទោសៈ មោហៈ ដោយគ្រា ដោយខណៈ , ការចម្រើនសមថភាវនា ក៏មានសតិ និងបញ្ញាដែរ អ្នកដែលប្រាថ្នាចម្រើនឈានចិត្ត ក៏ត្រូវដឹងបច្ច័យដែលធ្វើឲ្យសម្រេចឈាន ត្រូវដឹងថា អ្វីជាឧបសគ្គនៃការសម្រេចឈាន ត្រូវដឹងសភាពរបស់ចិត្តថា ប្រកបជាមួយអង្គរបស់ឈាន ដល់ថ្នាក់អាចសម្រេចជាឈានចិត្តហើយឬនៅ នឹងត្រូវដាស់-តឿនចិត្តឲ្យក្លាហានក្នុងសម័យដែលគួរដាស់តឿនចិត្តដោយន័យផ្សេង ៗ ដូច្នោះ ការចម្រើនសមថភាវនា ទើបត្រូវមានទាំងសតិ និង បញ្ញា ផ្សេងគ្នាពីការចម្រើនវិបស្សនា ការចម្រើនសមថភាវនា មិនមានលះបង់ការ

សេចក្តីឃើញខុសថា ជាតួខ្លួនទេ , បញ្ញាដែលកើតពីការចម្រើនវិបស្សនា-នាភាវនា ទើបធ្វើឲ្យមានការលះបង់សេចក្តីឃើញខុសថា ជាតួខ្លួនបាន ។

ចំណុចសំខាន់ក្នុងការចម្រើនវិបស្សនា សូម្បីក្នុងខាងដើម ក៏គឺ ការអប់រំចម្រើនបញ្ញាដើម្បីដឹងសភាវធម៌តាមសេចក្តីពិត ប្រសិនបើគិតថា ត្រូវចម្រើនសមថភាវនាមុន ចម្រើនវិបស្សនា ដើម្បីឲ្យកើតសតិច្រើន ៗ សម្មាទិដ្ឋិក្នុងមគ្គមានអង្គ ៨ ក៏កើតមិនបាន , កុំភ្លេចថា សម្មាសតិ និង សម្មាសមាធិ នឹងត្រូវកើតរួមជាមួយសម្មាទិដ្ឋិ ទើបជាអង្គរបស់មគ្គមានអង្គ ៨ ។

ស- អ្នកដែលមានបសាទមិនល្អ ចម្រើនសមថភាវនាឲ្យចិត្តស្ងប់ជាមុន ទើបចម្រើនវិបស្សនា មិនប្រសើរឬ ?

ឆ- អ្នកដែលចម្រើនសមថភាវនា ព្រោះមានឧបនិស្ស័យសន្សំមកឲ្យជាអ្នកមានប្រក្រតីចម្រើនសមថៈ ផ្សេងគ្នាជាមួយអ្នកដែលចម្រើនវិបស្សនាភាវនា ព្រោះគិតថា ត្រូវចម្រើនសមថភាវនា ដើម្បីឲ្យមានសតិច្រើន ៗ ជាមុន ទើបចម្រើនវិបស្សនាបាន ។

ចំពោះអ្នកមានបសាទមិនល្អ នឹងសិក្សាព្រះធម៌ ហើយប្រព្រឹត្ត



បដិបត្តិតាមព្រះធម៌ ក៏បានយល់អំពីជីវិតច្រើនឡើង ការយល់អំពីជីវិតនឹងមានប្រយោជន៍យ៉ាងប្រសើរដល់គេ តែម្យ៉ាង ។

ស- មានអ្នកខ្លះប្រាប់ថា អ្នកមានចិត្តរាយមាយ មិនគួរសិក្សាធម៌ព្រោះកាន់តែធ្វើឲ្យសោប់សោល់ច្រើនឡើង គួរបដិបត្តិប៉ុណ្ណោះ ។

ឆ- យើងមានចិត្តសោប់សោល់ មុននឹងបានសិក្សាធម៌ យើងកើតមកព្រោះអវិជ្ជា ព្រោះអវិជ្ជានោះឯង ជាបច្ច័យឲ្យកើត , យើងមានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត មានលោភៈ ទោសៈ មោហៈ ដែលកើតពីការដឹងអារម្មណ៍ផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត តែយើងមិនដឹងសភាវធម៌ទាំងឡាយនោះតាមសេចក្តីពិត ទើបយើងមានអវិជ្ជា ។

បើសិក្សា និង ពិចារណាធម៌ ក៏ផ្តើមយល់អំពីជីវិតបានត្រឹមត្រូវ សេចក្តីយល់ត្រឹមត្រូវនោះ ធ្វើឲ្យយើងសោប់សោល់ដូចម្តេចបាន ប្រសិនបើយើងចម្រើនវិបស្សនា ដោយមិនបានសិក្សាឲ្យយល់ យើងក៏មិនដឹងថា អ្វីជាការបដិបត្តិត្រូវ អ្វីជាការបដិបត្តិខុស យើងអាចច្រឡំវិបស្សនានឹងសមថៈ ហើយយើងអាចគិតថា ត្រូវចម្រើនសមថៈមុន ទើបចម្រើន

វិបស្សនា , យើងអាចគិតថា នឹងតាំងចិត្តឲ្យសតិកើតបាន បើដូច្នោះក៏មិនដឹងលក្ខណៈរបស់សម្មាសតិ ក្នុងមគ្គមានអង្គ ៨ , យើងមិនដឹងថាសតិជាអនត្តា យើងនឹងប្រកាន់សតិជាតួខ្លួន ផល ក៏គឺ ការប្រកាន់មាំថាជាតួខ្លួនជំនួស , យើងអាចគិតថា យើងដឹងសភាវធម៌ និង ដឹងការកើត-រលត់របស់សភាវធម៌ តែតាមសេចក្តីពិត យើងមិនដឹងអ្វីឡើយ យើងវង្វេងជឿថា ដឹងសច្ចធម៌ហើយ យើងមិនគួរភ្លេចថា ការសិក្សាព្រះធម៌ ជាបច្ច័យដ៏សំខាន់នៃការចម្រើនមគ្គមានអង្គ ៨ ។

ស- ប៉ុន្តែអ្នកដែលផ្តើមចម្រើនសតិប្បដ្ឋាន មិនអាចនឹងតាំងមាំក្នុងនាមធម៌ និង រូបធម៌បាន គេមិនគួរទៅកាន់កន្លែងដែលចំពោះ ដូចជាសម្នាក់បដិបត្តិដែលស្ងាត់ឬ? មនុស្សដោយច្រើនមានការច្របូកច្របល់ក្នុងជីវិតប្រចាំថ្ងៃ រហូតចម្រើនសតិមិនបាន នៅឯសម្នាក់បដិបត្តិ គេរមែងអាចតាំងចិត្តចម្រើនសតិប្បដ្ឋាន និង តាំងមាំក្នុងនាម-រូប បាន ។

ឆ- ការគិតនឹងទៅសម្នាក់បដិបត្តិ ដើម្បីតាំងចិត្តចម្រើនសតិនោះព្រោះមានការឃើញខុសថា មានតួខ្លួន , សម្នាក់បដិបត្តិមានប្រយោជន៍ក្នុងវិស័យចេះដឹងព្រះធម៌ តែមិនគួរគិតថា ត្រូវទៅសម្នាក់បដិបត្តិដើម្បី



ចម្រើនសតិ ការយល់ត្រូវ ជាបច្ច័យដល់ការចម្រើនសតិប្បដ្ឋាន ។

សម្នាក់បដិបត្តិ គេអាចត្រេកអរ ជាប់ជំពាក់ក្នុងសភាពស្ងប់ស្ងាត់ដែលជាការប្រកាន់មាំ និង អាចជាប់ជំពាក់ក្នុងសភាពស្ងប់ស្ងាត់ច្រើនឡើង ៗ គ្រប់ពេល បើមានអ្វីដែលមិនស្ងប់ ក៏ជាបច្ច័យឲ្យកើតទោសៈ និង កាលបើត្រឡប់មកជាជីវិតប្រក្រតីប្រចាំថ្ងៃ ក៏ចម្រើនសតិមិនបាន ព្រោះជីវិតប្រចាំថ្ងៃមិនមានការស្ងប់ ។

អ្នកខ្លះគិតថា គេ “ ចូលបដិបត្តិ ” បើនៅសម្នាក់បដិបត្តិ និង “ ចេញចាកបដិបត្តិ ” បើជាជីវិតប្រក្រតីប្រចាំថ្ងៃ ការចម្រើនវិបស្សនាមិនមាន “ គេ ” នឹង “ ចេញ ” , គួរចម្រើនសតិគ្រប់ពេល មិនថានឹងនៅទីណាក៏ដោយ ។

ស- បានជ្រាបថា អ្នកដែលផ្តើមចម្រើនវិបស្សនា គួរធ្វើអ្វី ៗ យឺត ៗ ដើម្បីឲ្យមានសតិច្រើន ៗ គួរទទួលទានអាហារយឺត ៗ និង ដើរយឺត ៗ ផង ។

ឆ- វេលាលើកដៃយឺត ៗ ដើម្បីឲ្យមានសតិច្រើន ៗ នោះ ចិត្តប្រភេទណា ជាបច្ច័យឲ្យធ្វើយ៉ាងនោះ មានសេចក្តីត្រូវការអ្វីខ្លះឬទេ? ។

ស- មាន មានសេចក្ដីត្រូវការសតិ ។

ឆ- បើយ៉ាងនោះ ក៏ជាលោកមូលចិត្ត លោកគិតដល់សតិដោយសេចក្ដីត្រូវការ គិតដល់សភាវធម៌ដែលមិនទាន់ប្រាកដ ជាប់ជំពាក់ក្នុងវត្ថុដែលនៅមិនទាន់កើតឡើង ជំនួសការរលឹកដឹងវត្ថុដែលប្រាកដក្នុងខណៈនោះ លោកមិនដឹងខ្លួនថា កំពុងត្រូវការសតិ តែការឃើញ ការឮកំពុងប្រាកដ ក៏មិនដឹងលក្ខណៈរបស់សភាវធម៌នោះ ៗ ដូច្នោះទើបមានតួខ្លួនជាអ្នកត្រូវការ មានតួខ្លួនជាអ្នកឃើញ ជាអ្នកឮ សូមកុំភ្លេចថា ចំណុចសំខាន់ក្នុងការចម្រើនវិបស្សនា គឺ ដើម្បីលះបង់ការឃើញខុសថា ជាតួខ្លួនឲ្យអស់ ។

ខណៈទទួលទានអាហារ កិលេសរមែងកើត ព្រោះនៅមិនទាន់បានលះឲ្យអស់ អាចពេញចិត្ត ឬ ទាស់ចិត្ត ក្នុងអាហារដែលកំពុងទទួលទាន ប៉ុន្តែសតិក៏រលឹកដឹងសភាវៈរបស់នាមធម៌ទាំងនោះបាន , បើទទួលទានអាហារយូរ ៗ ដើម្បីឲ្យមានសតិច្រើន ៗ ក៏ជាការជាប់ជំពាក់ក្នុងសតិ អ្នកខ្លះក៏ប្រាប់ថា គេ “ តាំងសតិ ” ខណៈទទួលទានអាហារ ពាក្យនិយាយរបស់គេបញ្ជាក់ថា មានសេចក្ដីត្រូវការសតិ និង មានការឃើញខុសថា



ជាតួខ្លួន , អ្នកដែលដើរតាមបែប ( ដែលតាំងឡើងជាក្រិតក្រម ) ដើម្បីឲ្យមានសតិច្រើន ៗ ក៏មានន័យដូចគ្នា គេត្រូវការសតិ និងមានការឃើញថា មានតួខ្លួន ។

យើងមិនគួរភ្លេចដល់អរិយសច្ចធម៌ ទី ២ ដែលបានដល់ តណ្ហា ដែលជាហេតុឲ្យកើតទុក្ខ , ដរាបណាមានសេចក្ដីត្រូវការនាមធម៌ រូបធម៌ ក៏មានជាតិ ( ការកើត ) មិនផុតពីសេចក្ដីទុក្ខឡើយ , បើត្រូវការចម្រើនវិបស្សនា និង ប្រាថ្នាផល ក៏ឈ្មោះថា ភ្លេចអរិយសច្ចធម៌ទី ២ ដូចជា អ្នកចម្រើនសតិមិនទាន់បានប៉ុន្មានផង ក៏ប្រាថ្នាចង់ដឹងសភាវៈដែលផ្សេងគ្នានៃការឃើញ និង ពណ៌ ( វត្ថុដែលប្រាកដផ្លូវភ្នែក ) , ការបានឮ និង សំឡេង ប្រាថ្នាចង់ឃើញច្បាស់ការកើតរលត់របស់នាមធម៌ និង រូបធម៌ ជាដើម ។ ប្រសិនបើជាប់ជំពាក់ប្រាថ្នាចង់បានញាណផ្សេង ៗ ក៏មិនអាចដឹងច្បាស់នូវសច្ចធម៌ឡើយ , ការចម្រើនមគ្គមានអង្គ ៨ ត្រូវចម្រើនយូរ ៗ ទើបកម្ចាត់ការឃើញខុសថា ជាតួខ្លួនបាន បញ្ញាត្រូវដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ទាំងឡាយដែលប្រាកដ បញ្ញាចម្រើនឡើងបាន ក៏ព្រោះការរលឹកដឹងលក្ខណៈរបស់នាមធម៌ និងរូបធម៌ រហូត

បានដឹងច្បាស់ ។

ស- ពេលមានសតិច្រើន ៗ ក៏មានការស្ងប់ច្រើន ដឹងខ្លួនពេញចិត្ត សេចក្តីស្ងប់ មិនសូវបានចម្រើនបញ្ញាឲ្យមុតស្រួចឡើង ។

ឆ- វេលាមានសតិ ក៏កម្ចាត់អកុសលខណៈនោះចេញបាន និង មានសេចក្តីស្ងប់ ដូច្នោះក៏នឹងឃើញបានថា ការចម្រើនមគ្គមានអង្គ ៨ ក៏មានសេចក្តីស្ងប់ផងដែរ , ឯកគ្គតាចេតសិក ដែលកើតជាមួយចិត្តដឹង លក្ខណៈរបស់នាមធម៌ រូបធម៌ ផ្សេងគ្នានឹងឯកគ្គតាចេតសិកដែលកើត ក្នុងលោភមូលចិត្ត ដែលជាសភាវធម៌មិនស្ងប់ ។

មានសេចក្តីស្ងប់ច្រើនប្រភេទ កាលបានសម្រេចអរិយសច្ចធម៌ ជា ព្រះអរហន្ត ក៏កម្ចាត់កិលេសបានជាសមុច្ឆេទ ដូច្នោះ ព្រះនិព្វាន ទើប ស្ងប់ពិត ។

បើត្រេកអរក្នុងសេចក្តីស្ងប់ ក្នុងខណៈមានសតិ ក៏គួរដឹងថា សេចក្តី ត្រេកអរនោះ ត្រឹមតែជានាមធម៌មួយប្រភេទ បើមិនរលឹកដឹងដូច្នោះ ក៏ មានការឃើញខុសថា ជាតួខ្លួន នឹងឃើញបានថា កិលេសក្រាស់ណែន យ៉ាងណា ខណៈដែលវង្វេងភ្លេចសតិ ក៏មានតួខ្លួនជាអ្នកសោកស្តាយ



ថា ខ្លួនវង្វេងភ្លេចសតិទៅហើយ និង កាលបើមានសតិកើតឡើង ក៏មាន តួខ្លួនត្រេកអរថា មានសតិ , ដូច្នោះ ការរលឹកដឹងលក្ខណៈរបស់ សភាវធម៌ទាំងឡាយដែលប្រាកដ ទើបជាប្រការសំខាន់ដែលកម្ចាត់បង់ ការប្រកាន់មាំចំពោះសភាវធម៌ទាំងឡាយបាន ។

ប្រសិនបើត្រេកអរក្នុងការមានសតិច្រើន ៗ ក៏មិនគួរគិតថា សម្រេច ធម៌ហើយ គួរចម្រើនបញ្ញាឲ្យដឹងលក្ខណៈរបស់នាមធម៌ រូបធម៌ ជាក់ ច្បាស់ឡើង ដូច្នោះ សម្មាវាយាមៈ ( សេចក្តីព្យាយាមត្រូវ ) ទើបជា អង្គមគ្គ ដែលខ្វះមិនបានឡើយ ក្នុងមគ្គមានអង្គ ៨ ។

ដូចដែលយើងឃើញហើយថា សម្មាទិដ្ឋិ និង សម្មាសង្កប្បៈ ជា អង្គរបស់បញ្ញា ក្នុងមគ្គមានអង្គ ៨ , សម្មាវាចា សម្មាកម្មន្តៈ និង សម្មាអាជីវៈ ជាអង្គរបស់សីល ក្នុងមគ្គមានអង្គ ៨ , សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ ជាអង្គរបស់សមាធិ ក្នុងមគ្គមានអង្គ ៨ ។ បើអង្គមគ្គទាំងនោះចម្រើនឡើង សេចក្តីដឹងសភាពរបស់នាមធម៌ រូបធម៌ ក៏ជាក់ច្បាស់ ដូច្នោះ បញ្ញា ការដឹងយ៉ាងនេះ ទើបជាការកម្ចាត់បង់ ការប្រកាន់មាំនាមធម៌ និង រូបធម៌ បាន ។

ស- ក្នុងទីឃនិកាយ មហាសតិប្បដ្ឋានសូត្រ មើលឃើញថា អារម្មណ៍ដែលជាសមថកម្មដ្ឋាន ក៏រួមចូលនៅក្នុងសតិប្បដ្ឋាន ៤ ដែរ ដូចជា អានាបានស្សតិ អសុភកម្មដ្ឋាន និង កាយគតាសតិ រួមក្នុងកាយានុបស្សនា ហេតុអ្វីបានជាមិនបែកសមថកម្មដ្ឋានចេញពីវិបស្សនាកម្មដ្ឋាន មិនគួរឲ្យលាយឡំគ្នា ។

ឆ- ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌គ្រប់ប្រការ ដែលមានពិត ដោយព្រះមហាករុណាគុណ ព្រះអង្គទ្រង់ត្រាស់ដឹងអធ្យាស្រ័យរបស់បុគ្គលទាំងឡាយ ហេតុនោះ ទ្រង់ទើបសម្តែងធម៌ដើម្បីអនុគ្រោះ ដោយន័យប្រការផ្សេង ៗ ព្រះអង្គទ្រង់សម្តែងកុសលធម៌គ្រប់ប្រភេទ , ការចម្រើនសមថភាវនា និង វិបស្សនាភាវនានោះ ផ្សេងគ្នា តែកម្មដ្ឋានខ្លះ ក៏ជាអារម្មណ៍បានទាំងសមថភាវនា និងវិបស្សនាភាវនា ដូចជាអានាបានស្សតិ បដិកូលមនសិការ ក៏ជាអារម្មណ៍របស់សមថភាវនា និង ក៏ជាអារម្មណ៍របស់វិបស្សនាភាវនាបាន ។

សភាវធម៌ដែលមានពិត ជាអារម្មណ៍របស់សតិបានទាំងអស់ កាលបានសិក្សាព្រះធម៌ ក៏នឹងឃើញថា មានវត្ថុច្រើនយ៉ាងក្នុងលោក ដែល



ជាស់តឿនឲ្យរលឹកដល់សភាពការពិត ដូចជា យើងអាចរលឹកដល់ចំណែកផ្សេង ៗ របស់រាងកាយ ដូចជា សក់ រោម ក្រចក ធ្មេញ ស្បែក ... ជាដើម ក្នុងជីវិតប្រចាំថ្ងៃ យើងមិនបានសង្កេតចំណែកផ្សេង ៗ នៃរាងកាយទាំងឡាយនេះខ្លះទេឬ , មនុស្សគ្រប់រូប មានសក់ ក្រចក ធ្មេញ ស្បែក មិនពិតឬ ដែលចំណែកផ្សេង ៗ នៃរាងកាយជាបដិកូលប្រែប្រួល? ធ្វើឲ្យរលឹកដល់សេចក្តីមិនទៀងបាន យើងមានការវង្វេងភ្លេចសតិ តែភាពបដិកូលរបស់សក់ ក្រចក ធ្មេញ ស្បែក និង ចំណែកដទៃរបស់រាងកាយ ក៏ធ្វើឲ្យរលឹកដល់សភាពពិតបាន ធ្វើឲ្យសតិរលឹកដឹងសភាវធម៌ដែលបានប្រាកដក្នុងខណៈនោះ , សតិអាចរលឹកដឹងនាមធម៌ដែលពិចារណាធម៌ ហើយសតិក៏រលឹកដឹងលក្ខណៈរបស់នាមធម៌ និងរូបធម៌ដទៃ ៗ ដែលប្រាកដតាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត , ខណៈដែលពិចារណាសភាវធម៌ ក៏មានសេចក្តីស្ងប់ មិនមានលោភៈ ទោសៈ មោហៈ យើងមិនគួរជាប់ជំពាក់ក្នុងសេចក្តីស្ងប់ខណៈនោះ និងមិនគួរតាំងចិត្តឲ្យស្ងប់ ដើម្បីឲ្យកើតសតិច្រើន ៗ , សេចក្តីស្ងប់កើតឡើង ព្រោះហេតុបច្ច័យ បើមិនត្រេកអរជាប់ជំពាក់ក្នុងសេចក្តី

ស្ងប់នោះ ក៏រមែងនឹងរលឹកដឹងសភាវធម៌ដែលប្រាកដក្នុងខណៈនោះ ។

អារម្មណ៍ ដែលធ្វើឲ្យសតិរលឹកដឹងសភាវធម៌ ដែលប្រាកដនោះ ផ្សេងគ្នា តាមអធ្យាស្រ័យរបស់បុគ្គលដែលសន្សំមករៀង ៗ ខ្លួន ដោយហេតុនោះ ព្រះមានព្រះភាគទ្រង់សម្តែងធម៌គ្រប់យ៉ាងដែលមានពិត , អ្នកខ្លះក៏មានអធ្យាស្រ័យរលឹកដល់អសុក កាលឃើញមនុស្សស្លាប់ ឬសត្វស្លាប់ ក៏ធ្វើឲ្យរលឹកដល់ភាពមិនទៀង តែចំពោះអ្នកខ្លះទៀត ការរលឹកដល់អសុក ឬការចម្រើនបដិកូលនៃរាងកាយ រមែងមិនប្រសើរ ។ តែមានអធ្យាស្រ័យក្នុងការរលឹកដល់សេចក្តីស្លាប់ ( មរណស្សតិ ) ការគិតដល់អាយុរបស់ជីវិតដែលមិនយឺនយូរ ធ្វើឲ្យអ្នកនោះឯងគ្របសង្កត់លោភៈ និង ទោសៈ បាន ។

លោកនេះពេញទៅដោយវត្ថុដែលជាស់តឿនឲ្យចម្រើនសតិ ដូច្នោះទើបមិនគួរមានទុក្ខសោកជាមួយវត្ថុណា ៗ ដែលកើតឡើងក្នុងជីវិត , វត្ថុទាំងអស់ ជាសតិប្បដ្ឋាន ពេលដែលសំឡឹងមើលកញ្ចក់ ឃើញខ្លួនឯងកាន់តែចាស់ ក៏ជាវត្ថុដែលក្រើនរំលឹកឲ្យចម្រើនសតិ ពេលឃើញសក់ស្កូវរបស់ខ្លួនឯង ឬរបស់អ្នកដទៃ ក៏ជាសតិប្បដ្ឋានបាន ។ ក្នុងជីវិត



ប្រចាំថ្ងៃ មិនមានវត្ថុបដិកូលដែលគួរឲ្យខ្ពើមច្រើន ទេឬ ? តួយ៉ាងដូចជា សរសៃសក់ក្នុងអាហារ ក្លិនមាត់របស់ខ្លួនឯង និងរបស់អ្នកដទៃជាដើម , វត្ថុទាំងនោះបានក្រើនរំលឹក ឲ្យរលឹកដឹងសភាវធម៌ក្នុងខណៈនោះបានធ្វើឲ្យទៅជាវត្ថុដែលមានប្រយោជន៍ជាទីបំផុតក្នុងជីវិត គឺការចម្រើនបញ្ញា ។

ការរលឹកដល់ការអប់រំសន្សំរបស់ខ្លួនឯង ក៏ធ្វើឲ្យសតិរលឹកដឹងសភាវធម៌ក្នុងខណៈនោះបាន យើងអាចសង្កេតដឹងថា មានការប្រកាន់មាំជ្រាលជ្រៅ ដែលបានសន្សំមករាប់ជាតិមិនអស់ យើងនៅចង់សន្សំការប្រកាន់មាំនោះឲ្យកពូនច្រើនឡើងទៀត ឬថា ត្រូវការរកផ្លូវដែលនាំទៅកាន់ការរលត់សេចក្តីប្រកាន់នោះ ? សូម្បីអកុសលចិត្តរបស់ខ្លួនឯង ក៏ជាវត្ថុដែលជួយក្រើនរំលឹក ឲ្យរលឹកដឹងសភាវធម៌ក្នុងខណៈនោះបាន ។

ក្នុងគ្រាខ្លះ យើងក៏មិនបានរលឹកដឹងចិត្តរបស់ខ្លួនឯង តែក៏អាចរលឹកដឹងចិត្តរបស់អ្នកដទៃ អាចដឹងអកុសលចិត្តរបស់អ្នកដទៃ ដូចជា សេចក្តីស្រឡាញ់ សេចក្តីកង្វល់ ភាពល្ងង់ខ្លៅ និង សេចក្តីសង្ស័យរបស់បុគ្គលដទៃ និង ក៏អាចនឹងដឹងកុសលចិត្តរបស់ខ្លួន ដូចជា សេចក្តីអាណិតអាសូ និង សេចក្តីករុណាដល់អ្នកដទៃ , ចិត្តរបស់អ្នកដទៃ

ជាសតិប្បដ្ឋាន បានទេ ? ពេលសតិដឹងថា ការដឹងចិត្តរបស់អ្នកដទៃនោះ ជានាមធម៌ ខណៈនោះក៏មិនមានការឃើញខុសថា មានតួខ្លួនដែលដឹងចិត្តរបស់អ្នកដទៃ ។

មិនមានសភាវធម៌ណា ដែលមិននៅក្នុងសតិប្បដ្ឋាន ការចម្រើនមគ្គមានអង្គ ៨ នោះ មិនត្រូវធ្វើអ្វីឲ្យស្មុគស្មាញទេ ជីវិតប្រចាំថ្ងៃរបស់យើង ជាធម៌ដែលនៅជិតខ្លួនជាទីបំផុត ដែលសតិរលឹកដឹងបានគ្រប់ពេល ។ វត្ថុទាំងអស់ក្នុងលោក ជាគ្រឿងជាស់តឿនយើងឲ្យចម្រើនមគ្គមានអង្គ ៨ រហូតបានសម្រេចដល់ទីរំលត់លោភៈ ទោសៈ មោហៈ យ៉ាងប្រាកដ ។

ក្នុងសំយុត្តនិកាយ មហាវារវគ្គ កុក្កុដារាមសូត្រទី ២ មានសេចក្តីថា ក្នុងកន្លែង ( កុក្កុដារាម ជិតនគរ ) បាដលិបុត្ត ព្រះភទ្ទៈចូលទៅរកព្រះអានន្ទ ហើយសួរថា “ អាវុសោ អានន្ទ ដែលហៅថា ព្រហ្មចារ្យ ៗ ដូច្នេះ ព្រហ្មចារ្យដូចម្តេចហ្ន៎ ទីបំផុតព្រហ្មចារ្យយ៉ាងណា ” ។

អា- “ សាធុ ៗ អាវុសោ ភទ្ទៈ ........ អរិយមគ្គដែលប្រកបដោយអង្គ ៨ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ



សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ និង សម្មាសមាធិ នេះឯង ជាព្រហ្មចារ្យ ការអស់ទៅនៃរាគៈ ទោសៈ មោហៈ នេះជាទីបំផុតរបស់ព្រហ្មចារ្យ ។ ”

---

សៀវភៅដែលរៀបរៀងផ្សាយហើយ ៖

១ អភិធម្មត្ថវិភាវិនីដីកា ៩ បរិច្ឆេទ ៩ ក្បាល

២ មហាបដ្ឋាន ១៣ ក្បាល

៣ បដិច្ចសមុប្បាទទីបនី ក្បាលទី ១

៤ មហា-ចូឡទុក្ខក្ខន្ធសូត្រ ព្រះពុទ្ធដីកាប្រែ និង អដ្ឋកថា

៥ មេត្តសូត្រ ព្រះពុទ្ធដីកាប្រែ និង អដ្ឋកថា

៦ វិតក្កសណ្ឋានសូត្រ ព្រះពុទ្ធដីកាប្រែ និង អដ្ឋកថា

៧ ព្រហ្មយានភាគ ១ ពោលអំពីមរណស្សតិ និង វិសុទ្ធ ៧

៨ ព្រហ្មយានភាគ ២ ពោលអំពីព្រហ្មវិហារកម្មដ្ឋាន

បាត់ដំបង , ថ្ងៃអាទិត្យ ១០ កើត ខែកត្តិក ព.ស. ២៥៤៨

២១ - ១១ - ២០០៤